# ផ្លូវនៃបណ្តឹង




ការផ្សាយរបស់
សមាគម អាដហុក
២០០០

LIBRARY
INSTITUTE
៣២៥.
៩
www.budinst.gov.kh www.elibraryofcambodia.org

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ស្រុង ចាន់ណា** ម្ចាស់គេហទំព័រ៥000ឆ្នាំ

សូមគោរពថ្លែងអំណរគុណចំពោះ

**លោកវេជ្ជបណ្ឌិត ខ្វៅ ឃុនសំរ៉ង** ជាប្រធាន

**មូលនិធិខ្មែរសម្រាប់ការសិក្សា** www.ceefoundation.org

និង **ករុណាខ្មែរ** www.karunacambodia.org

ដែលបានអនុញ្ញាតដល់គេហទំព័រ៥000ឆ្នាំ

យកសៀវភៅនេះមកដាក់ផ្សាយបន្តជាធម្មទាន

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ ។

បណ្ណាល័យអេឡិចត្រូនិចខ្មែរ
eLibrary of Cambodia
www.elibraryofcambodia.org

៣២៥.៩

ឯកសារស្រាវជ្រាវ

# ផ្លូវនៃបណ្ដឹង

រៀបរៀងដោយ

លោកមេធាវី ហេង ពូង

កែសម្រួលដោយលោក ហ៊ុង ធីឫទ្ធិ

ចៅក្រមនៃតុលាការ ខេត្តកំពង់ឆ្នាំង

បោះពុម្ពលើកទី៣

ការផ្សាយរបស់

សមាគម អាដហុក

២០០០

BUDDHIST INSTITUTE LIBRARY
៥១២២/០០

www.budinst.gov.kh www.elibraryofcambodia.org

# មាតិកា

ទំព័រ


ជំពូកទី១ : អំពីសមត្ថកិច្ច ........ ១

ផ្នែកទី១ : តុលាការ ........ ១

ផ្នែកទី២ : នគរបាលយុត្តិធម៌ ........ ៤

ផ្នែកទី៣ : អយ្យការ ........ ៦

ផ្នែកទី៤ : សមាសភាព ........ ៦

ជំពូកទី២ : រដ្ឋអំណាចមូលដ្ឋាន និងអង្គការ សមាគមនានា ........ ៨

ផ្នែកទី១ : រដ្ឋអំណាចមូលដ្ឋាន ........ ៨

ផ្នែកទី២ : អង្គការ សមាគមនានា ........ ៩

ជំពូកទី៣ : មេធាវី និងការជ្រើសរើសមេធាវី ........ ១០

ផ្នែកទី១ : មេធាវី ........ ១០

ផ្នែកទី២ : ការជ្រើសរើសមេធាវី ........ ១២

ជំពូកទី៤ : បណ្តឹង ........ ១៤

ផ្នែកទី១ : បណ្តឹងលើកដំបូង ........ ១៥

ផ្នែកទី២ : គំរូពាក្យបណ្តឹងផ្សេងៗ ........ ១៩

ផ្នែកទី៣ : បណ្តឹងទាស់ ........ ៣៥

ផ្នែកទី៤ : បណ្តឹងឧទ្ធរណ៍ ........ ៣៧

ផ្នែកទី៥ : បណ្តឹងសាទុក្ខ ........ ៤២

ផ្នែកទី៦ : បណ្តឹងសើរើ ........ ៤៤



www.budinst.gov.kh www.elibraryofcambodia.org

**ស្នាដៃនេះ**

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីហ្សូ កូស៊ី-កៃ   វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage.  This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

# កថាមុខ

ឯកសារនេះ ចងក្រងឡើងសំរាប់ធ្វើការសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ គ្មានគំនិតអោយបុគ្គលណាមួយយកជាច្បាប់ ដើម្បីដើរប្តឹងផ្តល់គ្នានោះទេ ។ យើងដឹងហើយថា ការប្តឹងផ្តល់គ្នាមានតែការខាតបង់ និងការស្មុគស្មាញ សូម្បីកវីខ្មែរដ៏ល្បីល្បាញពីអតីតកាលដែលមានឈ្មោះថា **ភិរម្យភាសាអ៊ូ** ហៅ **ឱ៊ុយ** លោកក៏បានចងក្រងជាច្បាប់ក្រមង៉ុយទុកសំរាប់ប្រដៅជនប្រុស ស្រីគ្រប់ជំនាន់ផងដែរ " **ឯងប្តឹងទាត់ ក្តីទាល់តែក្រ អស់ឆ្លងអស់ចាន របស់ក៏ខាត របរក៏ខាន ដឹងអស់ប៉ុន្មាន នាំរាំចាញ់ឈ្នះ** "៕ ប៉ុន្តែមនុស្សរស់នៅក្នុងសង្គមតែងតែធ្វើសកម្មភាពជាប់ជាប្រចាំ មិនអាចជៀសផុតពីកំហុសឬទំនាស់បានឡើយ។

ដូច្នេះនៅពេលដែលជនណាម្នាក់ធ្វើខុស គឺកើតចេញជាបញ្ហា កាលបើមានបញ្ហាកើតឡើងមនុស្សតែងតែរិះរកវិធីផ្សេងៗដើម្បីបញ្ចប់វា ។ បើសិនជាបញ្ហានេះ ជាបញ្ហាបន្តិចបន្តួចងាយនឹងដោះស្រាយ គេអាចបញ្ចប់វាបានយ៉ាងឆាប់រហ័ស ដោយមិនចាំបាច់គិតដល់ផ្លូវច្បាប់ទេ ប៉ុន្តែបើបញ្ហានេះវាធ្ងន់ធ្ងរ ឬជាបញ្ហាពិបាកដោះស្រាយ គេនឹងរកដំណោះស្រាយតាមផ្លូវច្បាប់មិនខានឡើយ ។ ការស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់ គឺជាវិធីមួយដ៏ល្អអាចជៀសវាងបាននូវហិង្សា ហើយសអោយឃើញថា សិទ្ធិ និងសេរីភាពរបស់មនុស្សត្រូវបានគេគោរពដូចរដ្ឋធម្មនុញ្ញមាត្រា៣៩ បានចែងថា " **ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ** "។

សិទ្ធិនេះយើងបានឃើញប្រជាពលរដ្ឋខ្មែរភាគច្រើន បានប្រើប្រាស់ជាហូរហែ ប៉ុន្តែអ្វីដែលជាផលវិបាករបស់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់សិទ្ធិនេះ គឺដោយសារការមិនសូវយល់អំពីរបៀបរបបនៃការធ្វើបណ្តឹង ។

ឆ្លងកាត់សកម្មភាពការងារ ចាប់តាំងពីឆ្នាំ១៩៩២មក សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា " **អាដហុក** " បានទទួលនូវពាក្យបណ្តឹង និងសំណូមពររបស់ប្រជាពលរដ្ឋជាច្រើន ហើយសមាគមតែងតែជួយរំលែកនូវការលំបាករបស់ប្រជាពលរដ្ឋ ដោយជួយពន្យល់ណែនាំអំពីការធ្វើបណ្តឹងទៅកាន់សមត្ថកិច្ច ជួយចាត់ការបណ្តឹង ជួយអន្តរាគមន៍បន្ថែម និងជួយការពារក្តីរហូតដល់ប្រជាពលរដ្ឋទទួលបាននូវដំណោះស្រាយ ជាពិសេសករណីរំលោភសិទ្ធិមនុស្ស ។

ហេតុនេះ ដើម្បីជួយប្រជាពលរដ្ឋយើងអោយកាន់តែយល់ និងអាចមានលទ្ធភាពធ្វើបណ្តឹងទៅកាន់សមត្ថកិច្ចបានដោយខ្លួនឯង សមាគមសូមបង្ហាញនូវរបៀបរបប និងទិសដៅខ្លះៗតាមរយៈឯកសារនេះ ។

www.budinst.gov.kh www.elibraryofcambodia.org

## ជំពូក១

## អំពីសមត្ថកិច្ច

សមត្ថកិច្ច គឺជាស្ថាប័នរដ្ឋដែលច្បាប់ប្រគល់សិទ្ធិ អំណាច អោយទទួលដោះស្រាយបណ្តឹង ។ តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាអនុម័តឆ្នាំ១៩៩៣ មាត្រា៣៩ចែងថា : " **ការដោះស្រាយបណ្តឹងជាសមត្ថកិច្ចរបស់តុលាការ** " គប្បីយើងស្វែងយល់អំពីសមត្ថកិច្ច ដែលមានកំណត់នៅក្នុងច្បាប់ដូចជា ៖

- រដ្ឋធម្មនុញ្ញ
- ច្បាប់ព្រហ្មទណ្ឌ
- ច្បាប់រដ្ឋប្បវេណី
- និងច្បាប់ផ្សេងៗទៀត

## ផ្នែកទី១

## តុលាការ

តុលាការជាសាលាជំរះក្តី សាលាជំរះក្តីនៃព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃមាន ៖

- តុលាការខេត្ត-ក្រុង
- តុលាការយោធា
- សាលាឧទ្ធរណ៍
- តុលាការកំពូល

www.budinst.gov.kh www.elibraryofcambodia.org

# តុលាការជាន់ទាប

## ១ - តុលាការខេត្ត-ក្រុង

តុលាការខេត្ត-ក្រុង ដែលតាំងនៅក្នុងខេត្តណាមានសមត្ថកិច្ចដោះស្រាយតែរឿងក្តីទាំងឡាយណា ដែលកើតឡើងនៅក្នុងរង្វង់ដែនដីនៃខេត្ត-ក្រុង ដែលតុលាការនោះតាំងនៅតែប៉ុណ្ណោះ ។

**ឧទាហរណ៍** : តុលាការរាជធានីភ្នំពេញអាចដោះស្រាយបានតែរឿងក្តី ដែលកើតមានឡើងនៅក្នុងរង្វង់ដែនដីនៃក្រុងភ្នំពេញតែប៉ុណ្ណោះ មិនអាចដោះស្រាយរឿងក្តីដែលកើតឡើងក្នុងរង្វង់ដែនដីនៃខេត្តកណ្តាលបានទេ ។

## ២ - តុលាការយោធា

តុលាការយោធាក៏ដូចជាតុលាការខេត្ត-ក្រុងដែរ តុលាការនេះមានតែមួយទេ តាំងនៅរាជធានីភ្នំពេញ មានសមត្ថកិច្ចលាតសន្ធឹងលើផ្ទៃប្រទេសទាំងមូល ហើយត្រូវដោះស្រាយតែចំពោះរឿងក្តីទាំងឡាយណាដែលបង្កឡើងដោយយោធិនប៉ះពាល់ដល់កងទ័ព ឬទ្រព្យសម្បត្តិ ឬវិន័យរបស់កងទ័ព ។

**មាត្រា១១ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ** ( UNTAC ) : "តុលាការយោធាទទួលជំនុំជំរះតែបទល្មើសយោធាទេ បទល្មើសយោធា គឺជាបទល្មើសដែលទាក់ទិនដល់យោធិន ទាំងយោធិនជាប់កិច្ចសន្យា ទាំងយោធិនកំណែន ហើយដែលពាក់ព័ន្ធដល់បទវិន័យយោធា ឬការខូចខាតទ្រព្យសម្បត្តិយោធា ។ បទឧក្រិដ្ឋ ឬបទល្មើស នឹងច្បាប់សាមញ្ញដែលប្រព្រឹត្តដោយយោធិននឹងត្រូវទទួលការជំនុំជំរះនៅតុលាការស៊ីវិល"។

**ឧទាហរណ៍** : ឈ្មោះ " ខ " ធ្វើទ័ពនៅអង្គភាពមួយក្នុងខេត្តកំពង់ស្ពឺ បានលួចយកអាវុធចំនួនពីរដើម ដែលជារបស់កងទ័ពនៃអង្គភាពនោះ នៅពេលដែលឈ្មោះ " ជ " ជាតំណាងអង្គភាពយោធាបានដឹង គាត់ក៏ប្តឹងទៅតុលាការយោធា ។

# តុលាការជាន់ខ្ពស់

## ៣ - សាលាឧទ្ធរណ៍

សាលាឧទ្ធរណ៍មានតែមួយទេ តាំងនៅរាជធានីភ្នំពេញ តុលាការនេះ មានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃប្រទេសទាំងមូល សាលាឧទ្ធរណ៍ទទួលដោះស្រាយបណ្តឹងឧទ្ធរណ៍របស់គូក្តី ដែល

www.budinst.gov.kh www.elibraryofcambodia.org

ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនានា របស់តុលាការថ្នាក់ក្រោមណាមួយ ដូចជាសេចក្តីសំរេចរបស់តុលាការខេត្ត-ក្រុង និងតុលាការយោធា ។

**ឧទាហរណ៍** : តុលាការខេត្តកំពង់ស្ពឺបានកាត់ក្តីអោយឈ្មោះ " គ " ឈ្នះឈ្មោះ " ខ " ឈ្មោះ " ខ " មិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលក្រមក៏ចូលទៅកាន់ការិយាល័យក្រឡាបញ្ជីនៃតុលាការ ខេត្តកំពង់ស្ពឺ ហើយប្រាប់ថា ខ្ញុំសុំប្តឹងឧទ្ធរណ៍ និងសាលក្រមលេខ១០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩៧ ត្រង់ចំណុចសេចក្តីសំរេចទាំងមូល ក្រឡាបញ្ជីក៏បានបំពេញទំរង់សេចក្តីសុំប្តឹងឧទ្ធរណ៍តាមការប្រាប់របស់ឈ្មោះ " ខ " ហើយអោយឈ្មោះ " ខ " ផ្តិតមេដៃលើពាក្យនេះ រួចហើយផ្តិតមេដៃលើសៀវភៅចុះបណ្តឹងឧទ្ធរណ៍ក្រឡាបញ្ជីនឹងប្រាប់ថា ២-៣ថ្ងៃក្រោយសូមទៅតាមដានសំណុំរឿងនៅសាលាឧទ្ធរណ៍ចុះ ។

## ៤ - តុលាការកំពូល

តុលាការកំពូលមានតែមួយទេ តាំងនៅរាជធានីភ្នំពេញ តុលាការនេះមានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃប្រទេសទាំងមូល និងទៅលើគ្រប់សាលាជំរះក្តី មានសមត្ថកិច្ចដោះស្រាយបណ្តឹងសាទុក្ខលើកទី១ និងលើកទី២ ដែលប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីកាលើកទីមួយ និងលើកទីពីររបស់សាលាឧទ្ធរណ៍ ។

ការដោះស្រាយបណ្តឹងសាទុក្ខលើកទីមួយ តុលាការកំពូលពិនិត្យសំរេចតែលើអង្គច្បាប់ទេ ។ បើលើកទីមួយ តុលាការកំពូលសំរេចថា តំកល់សាលដីការបស់សាលឧទ្ធរណ៍ទុកជាបានការពេញទាំងមូល សាលដីកាលើកដំបូង ឬលើកទីមួយរបស់តុលាការកំពូល គឺជាសាលដីកាអធិបតេយ្យបិទការប្តឹងតវ៉ា ។ បើតុលាការកំពូលបដិសេធសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ទាំងមូល ឬត្រង់ចំណុចណាមួយនៃសាលដីកា តុលាការនឹងបង្វិលសំណុំរឿងទៅអោយសាលាឧទ្ធរណ៍ពិនិត្យសំរេចឡើងវិញ ។

កាលបើសាលដីកាលើកទីពីររបស់សាលាឧទ្ធរណ៍បានចេញរួចហើយៗ បើគូក្តីណានៅមិនសុខចិត្តមានសិទ្ធិប្តឹងសាទុក្ខលើកទី២ទៅ តុលាការកំពូលៗ នឹងទទួលពិនិត្យសំរេចម្តងទៀត លើកទីពីរនេះតុលាការកំពូលពិនិត្យទាំងអង្គហេតុ ទាំងអង្គច្បាប់ ហើយសាលដីកាលើកទីពីរ របស់តុលាការកំពូលជាសាលដីកាអធិបតេយ្យបិទការប្តឹងតវ៉ា និងមានប្រសិទ្ធភាពអនុវត្តភ្លាមៗ ។ តុលាការនេះ ក៏មានសមត្ថកិច្ចពិសេសមួយទៀតដែរ គឺដោះស្រាយលើបណ្តឹងសើរើ ។

**ឧទាហរណ៍** : លោក A និងលោក B ប្តឹងផ្តល់គ្នាទាមទារដីចំការមួយកន្លែង ហើយត្រូវបានតុលាការខេត្តកណ្តាលកាត់ក្តីសំរេចប្រគល់ដីទំនាស់អោយលោក A តែលោក B មិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលក្រមទាំងមូលរបស់តុលាការខេត្តកណ្តាល គាត់ក៏ប្តឹងឧទ្ធរណ៍ ។ នៅពេលសាលាឧទ្ធរណ៍

www.budinst.gov.kh www.elibraryofcambodia.org

កាត់ក្ដី សាលាឧទ្ធរណ៍បានសំរេចប្រគល់ដីអោយលោក B វិញ ។ លោក A មិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ក៏ប្ដឹងសាទុក្ខទៅតុលាការកំពូល ។ នៅពេលកាត់ក្ដី តុលាការកំពូលបានពិនិត្យឃើញថា សាលាឧទ្ធរណ៍សំរេចសេចក្ដីមិនបានត្រឹមត្រូវតាមច្បាប់ តុលាការកំពូលក៏សំរេចបង្វិលសំណុំរឿងទៅអោយសាលាឧទ្ធរណ៍ពិនិត្យសំរេចឡើងវិញ ។

សាលាឧទ្ធរណ៍បានកាត់ក្ដីរឿងដដែលជាលើកទីពីរ សំរេចតំកល់សាលដីកាលើកទីមួយ របស់សាលាឧទ្ធរណ៍ទុកជាត្រឹមត្រូវដដែល ។ លើកទីពីរនេះ លោក A នៅតែមិនសុខចិត្តដដែល ក៏ប្ដឹងសាទុក្ខម្ដងទៀត តុលាការកំពូលក៏ទទួលកាត់ក្ដីជាលើកទីពីរ លើកទីពីរនេះ តុលាការកំពូលបានពិនិត្យកាត់ក្ដីទាំងអង្គហេតុ ទាំងអង្គច្បាប់ឃើញថា លោក A ត្រូវតែជាម្ចាស់ដីចំការទើបត្រឹមត្រូវ ក៏សំរេចប្រគល់ដីអោយលោក A ដោយតំកល់សាលក្រមរបស់តុលាការខេត្តកណ្ដាលទុកជាត្រឹមត្រូវពេញទាំងមូល ហើយតុលាការកំពូលក៏ប្រគល់សាលដីកាលើកទីពីររបស់ខ្លួន ទៅតុលាការខេត្តកណ្ដាលអោយអនុវត្តភ្លាម រឿងក្ដីក៏ត្រូវបានបញ្ចប់ជាស្ថាពរ ។

* ចំណាំ

ក្រៅពីតុលាការទាំងបួនខាងលើសព្វថ្ងៃនេះ អាចមានតុលាការពិសេសផ្សេងៗទៀត បើសិនជាមានច្បាប់ថ្មីកំណត់ដូចជា តុលាការការងារ តុលាការពាណិជ្ជកម្ម តុលាការរដ្ឋបាល ។ល។

## ផ្នែកទី២

# នគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ជានគរបាលតុលាការប្រតិបត្តិការទាំងឡាយនៃនគរបាលយុត្តិធម៌ស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់ព្រះរាជអាជ្ញា និងក្រោមការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចចាត់ចែងប្រតិបត្តិការការងារ :

- មន្ត្រីនគរបាលយុត្តិធម៌នៅកន្លែងបទល្មើសព្រហ្មទណ្ឌកើតមាន
- មន្ត្រីនគរបាលយុត្តិធម៌ខាងលំនៅដ្ឋានរបស់ជនល្មើស
- មន្ត្រីនគរបាលយុត្តិធម៌នៅកន្លែងដែលជនល្មើសត្រូវបានរកឃើញ
- ទទួលពាក្យបណ្ដឹងទាមទារបណ្ដឹងបរិហារ ព្រមទាំងរបាយការណ៍នគរបាលយុត្តិធម៌ទាក់ទងបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុនានា ។
- ចាត់ចែងប្រមូលភស្តុតាងនានា

www.budinst.gov.kh www.elibraryofcambodia.org

- អាចស្នើជំនួយពីកំលាំងសាធារណៈ
- ធ្វើកំណត់ហេតុ
- អាចទទួលលិខិតបង្គាប់អោយសួរជំនួស
- អាចសំរេចឃាត់ខ្លួនបានក្នុងរយៈពេល៤៨ម៉ោងយ៉ាងយូរ
- ក្នុងករណីរឿងឧក្រិដ្ឋ និងមជ្ឈឹមដាក់ស្តែងអាចសួរយកចម្លើយសាក្សីធ្វើការឆែកឆេរ និងរឹបអូសវត្ថុតាង អាចចាត់តាំងអ្នកជំនាញសំរេចឃាត់ខ្លួនជនលើស៤៨ម៉ោងយ៉ាងយូរ ចាប់បុគ្គលណាមួយ ប្រសិនបើមានភស្តុតាង ឬមានការសង្ស័យដែលមានមូលដ្ឋានច្បាស់លាស់ សំរេចធ្វើការចោទប្រកាន់បាន ។

ចាត់ទុកជាមន្ត្រីនគរបាលយុត្តិធម៌ ឬអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ រួមមាន :

១ - ព្រះរាជអាជ្ញា និងចៅក្រមទទួលបន្ទុកស៊ើបអង្កេត " ក្នុងភារកិច្ចតែប៉ុណ្ណោះ "
២ - ប្រធាន និងអនុប្រធានទាំងឡាយនៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ និងសេដ្ឋកិច្ច
៣ - ប្រធាន និងអនុប្រធានទាំងឡាយនៃនាយកដ្ឋានប្រឆាំងភេរវកម្ម
៤ - ស្នងការ និងស្នងការរងទាំងឡាយនៃនគរបាលខេត្ត-ក្រុង
៥ - ប្រធានការិយាល័យនគរបាលព្រហ្មទណ្ឌ និងសេដ្ឋកិច្ច
៦ - ប្រធានការិយាល័យប្រឆាំងភេរវកម្ម
៧ - ប្រធានការិយាល័យនគរបាលសន្តិសុខ
៨ - អធិការ និងអធិការរងនគរបាលស្រុក
៩ - ប្រធានប៉ុស្តិ៍នគរបាល " ចំពោះរឿងព្រហ្មទណ្ឌ "
១០- ប្រធានការិយាល័យនគរបាលចរាចរ និងប្រធានផ្នែកបទល្មើសចរាចរ " ចំពោះបទល្មើសចរាចរ " ។
១១- ប្រធាន និងមន្ត្រីទាំងឡាយនៃកងគម្រូតយោធា " ចំពោះបទល្មើសយោធា "
១២- មន្ត្រីនគរបាលព្រំដែន
១៣- អធិការគយ " ចំពោះបទល្មើសគយ "
១៤- មន្ត្រីរុក្ខាប្រមាញ់ និងនេសាទ

www.budinst.gov.kh www.elibraryofcambodia.org

## ផ្នែកទី៣

# អយ្យការ

- នៅអមតុលាការខេត្ត-ក្រុង និងតុលាការយោធាមានអយ្យការ
- នៅអមសាលាឧទ្ធរណ៍ និងតុលាការកំពូលមានមហាអយ្យការ
- អយ្យការមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង
- អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាបំពេញមុខងារជាមន្ត្រីរដ្ឋាភិបាល ជាអ្នកការពារច្បាប់របស់រដ្ឋ ។
- ចំពោះមុខសាលាជំរះក្តីផ្នែកព្រហ្មទណ្ឌ តំណាងអយ្យការត្រូវជាគូក្តីដើមជានិច្ច គឺធ្វើបណ្តឹងអាជ្ញាដោយចោទប្រកាន់ជនជាប់សង្ស័យ និងសុំអោយអនុវត្តច្បាប់លើជននោះ។
- ចំពោះមុខសាលាជំរះក្តីផ្នែករដ្ឋប្បវេណី តំណាងអយ្យការអោយយោបល់របស់ខ្លួន បើយល់ឃើញថាជាការគួរ ប៉ុន្តែក្នុងរឿងក្តីរដ្ឋប្បវេណីមួយចំនួន ដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬដល់ប្រយោជន៍អនីតិជន ឬអសមត្ថជន ។ល។ តំណាងអយ្យការត្រូវតាំងខ្លួនជាគូក្តីដើម ។
- រដ្ឋអាជ្ញាមានបេសកកម្ម ត្រូវទទួលពាក្យបណ្តឹង និងពាក្យបណ្តឹងបរិហារទាក់ទងបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ទោះជាពាក្យនោះចេញពីជនណាម្នាក់ ចេញមកពីមន្ត្រីនគរបាលយុត្តិធម៌ ឬក៏ចេញមកពីមន្ត្រីឯទៀត ដែលមានសមត្ថកិច្ចចាត់ការរឿងព្រហ្មទណ្ឌ ។

## ផ្នែកទី៤

# សមាសភាព

**តុលាការខេត្ត-ក្រុង**

ពេលបើកសវនាការជំនុំជំរះក្តី ត្រូវមានសមាសភាព :

- ចៅក្រមមួយរូបជាប្រធានសវនាការ
- តំណាងអយ្យការមួយរូបជាដើមបណ្តឹងអាជ្ញា ជាអ្នកចោទប្រកាន់ក្នុងរឿងក្តីព្រហ្មទណ្ឌ និងជាគូក្តីរណបក្នុងរឿងក្តីរដ្ឋប្បវេណីបំពេញភារកិច្ចជាអ្នកផ្តល់យោបល់ ។

www.budinst.gov.kh www.elibraryofcambodia.org

- ក្រឡាបញ្ជីមួយរូបជាលេខាកត់ត្រា
- មេធាវីរបស់គូក្ដីជាអ្នកចូលរួម បើសិនជាមាន

**សាលាឧទ្ធរណ៍**

ពេលបើកសវនាការត្រូវមានសមាសភាព :

- ចៅក្រមបីរូប មួយរូបជាចៅក្រមប្រធាន និងពីររូបជាចៅក្រមប្រឹក្សា
- តំណាងមហាអយ្យការមួយរូប បំពេញភារកិច្ចដូចតំណាងអយ្យការដែរ
- ក្រឡាបញ្ជីមួយរូប ជាលេខាកត់ត្រា
- មេធាវីរបស់គូក្ដីជាអ្នកចូលរួម បើសិនជាមាន

**តុលាការកំពូល**

ពេលបើកសវនាការជំនុំជំរះក្ដី ត្រូវមានសមាសភាព :

- ចៅក្រមប្រាំរូប មួយរូបជាចៅក្រមប្រធាន បួនរូបជាចៅក្រមប្រឹក្សាសំរាប់ជំនុំជំរះក្ដីលើបណ្ដឹងសាទុក្ខលើកទីមួយ ។
- តំណាងមហាអយ្យការមួយរូប
- ក្រឡាបញ្ជីមួយរូបជាអ្នកកត់ត្រា
- ចៅក្រមប្រាំបួនរូប មួយរូបជាចៅក្រមប្រធាន ប្រាំបីរូបជាចៅក្រមប្រឹក្សាសំរាប់ជំនុំជំរះលើបណ្ដឹងសាទុក្ខលើកទីពីរ ។
- តំណាងមហាអយ្យការមួយរូប
- ក្រឡាបញ្ជីមួយរូបជាអ្នកកត់ត្រា
- ជំនុំជំរះលើបណ្ដឹងសើរើមានចៅក្រមប្រាំបួនរូប មួយរូបជាចៅក្រមប្រធាន ប្រាំបីរូបជាចៅក្រមប្រឹក្សា ។
- មេធាវីរបស់គូក្ដីជាអ្នកចូលរួម បើសិនជាមាន
- តំណាងមហាអយ្យការមួយរូប
- ក្រឡាបញ្ជីមួយរូបជាអ្នកកត់ត្រា

www.budinst.gov.kh www.elibraryofcambodia.org

# ជំពូកទី២

# រដ្ឋអំណាចមូលដ្ឋាន និងអង្គការសមាគមនានា

## ផ្នែកទី១

## រដ្ឋអំណាចមូលដ្ឋាន

- រដ្ឋអំណាចមូលដ្ឋាន គឺជាបុគ្គល មន្ត្រី ឬនីតិបុគ្គលដែលមានភារកិច្ចគ្រប់គ្រងមើលការខុសត្រូវនៅក្នុងព្រំខណ្ឌនៃដែនដីរដ្ឋបាល ដែលខ្លួនគ្រប់គ្រង ។
- រដ្ឋអំណាចមូលដ្ឋានមានភូមិ ឃុំ ស្រុក ខេត្ត ក្រុង
- រដ្ឋអំណាចភូមិ ឃុំ ស្រុក ខេត្ត ក្រុងមានភារកិច្ចទទួលខុសត្រូវដោះស្រាយរាល់បញ្ហារដ្ឋប្បវេណី ដែលកើតមានឡើងនៅក្នុងរង្វង់ដែនដី ដែលខ្លួនគ្រប់គ្រង ។
- ទាក់ទងនឹងបញ្ហាបណ្តឹងខាងរដ្ឋប្បវេណី រដ្ឋអំណាចមូលដ្ឋានត្រូវទទួលធ្វើការពិនិត្យដោះស្រាយ និងបញ្ជូនទៅកាន់រដ្ឋអំណាចខ្ពស់ជាងតាមលំដាប់ថ្នាក់របស់ខ្លួន ឬស្ថាប័នមានសមត្ថកិច្ច ដើម្បីដោះស្រាយបន្ត ក្នុងករណីខ្លួនជារដ្ឋអំណាចមូលដ្ឋានថ្នាក់ក្រោមដោះស្រាយមិនចេញ ត្រូវបញ្ជូនផ្ទាល់មកតុលាការខេត្ត-ក្រុង ។
- ចំពោះរឿងក្តីព្រហ្មទណ្ឌ រដ្ឋអំណាចមូលដ្ឋានថ្នាក់ភូមិ ឃុំ ស្រុក ឬខេត្តជាអ្នកមានភារកិច្ចមុនគេ ។ កាលបើបានទទួលពាក្យបណ្តឹងព្រហ្មទណ្ឌអំពីបទល្មើសអ្វីមួយ ដែលកើតឡើងក្នុងដែនដីរបស់ខ្លួនគ្រប់គ្រង ត្រូវរាយការណ៍អោយមន្ត្រីនគរបាលយុត្តិធម៌ជាបន្ទាន់ ។ ជាបឋមត្រូវការពារកន្លែងកើតហេតុ ។
- ចំពោះរឿងក្តីរដ្ឋប្បវេណី រដ្ឋអំណាចមូលដ្ឋានធ្វើការផ្សះផ្សា សំរុះសំរួលអោយក្តីសះជានឹងគ្នា ដោយអោយឈប់ធ្វើការប្តឹងផ្តល់តទៅទៀត បើមិនបានសំរេចត្រូវបញ្ជូនទៅរដ្ឋអំណាចថ្នាក់លើរបស់ខ្លួន ឬស្ថាប័នមានសមត្ថកិច្ចធ្វើការផ្សះផ្សា ឬដោះស្រាយបន្ត ឬបញ្ជូនផ្ទាល់ទៅតុលាការខេត្ត-ក្រុង ។

គ្រប់រឿងក្តីទាំងអស់ មិនថារឿងក្តីព្រហ្មទណ្ឌ មិនថារឿងក្តីរដ្ឋប្បវេណីទេ រដ្ឋអំណាចមូលដ្ឋានគ្មានសិទ្ធិសំរេចលទ្ធផលអោយអ្នកនេះចាញ់ អ្នកនោះឈ្នះទេ ។

www.budinst.gov.kh www.elibraryofcambodia.org

- រដ្ឋអំណាចមូលដ្ឋាន អាចធ្វើជាតំណាង ដើម្បីទាមទារនូវដំណោះស្រាយផ្សេងៗ ជំនួសប្រជាពលរដ្ឋ ដែលស្ថិតនៅក្នុងរង្វង់ដែនដីរដ្ឋបាលរបស់ខ្លួនគ្រប់គ្រងទៅស្ថាប័នមានសមត្ថកិច្ច ជាពិសេសតំណាងអោយផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋខ្លួន ។

## ផ្នែកទី២

## អង្គការ សមាគមនានា

អង្គការ សមាគមនានាអាចជាអង្គការរដ្ឋ អង្គការសង្គម អង្គការមហាជន ដែលស្ថិតនៅក្នុងជួររដ្ឋាភិបាល ឬក្រៅរដ្ឋាភិបាល ជាអង្គការ សមាគមខ្មែរ ឬបរទេសដែលមានទីតាំង និងធ្វើសកម្មភាពក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបំរើលើគ្រប់វិស័យ ជាពិសេសវិស័យសិទ្ធិមនុស្សអាចទទួលចាត់ការនូវរាល់បញ្ហាដែលកើតឡើងនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា អាចធ្វើការដោះស្រាយដោយឯកឯងបាន ប៉ុន្តែចំពោះបញ្ហាដែលទាក់ទងនឹងវិស័យយុត្តិធម៌ ត្រូវជួយប្រជាពលរដ្ឋដោយជួយ ធ្វើអន្តរាគមន៍ទៅរដ្ឋអំណាច ឬស្ថាប័នមានសមត្ថកិច្ចរបស់រដ្ឋាភិបាល ដើម្បីដោះស្រាយ ។ ប្រជាពលរដ្ឋគ្រប់ជាតិសាសន៍ ដែលរស់នៅលើទឹកដីកម្ពុជាអាចទាមទារយុត្តិធម៌ ឬដំណោះស្រាយផ្សេងៗដោយស្នើតាមរយៈអង្គការ សមាគមទាំងនោះ អោយជួយដោះស្រាយ ឬជួយធ្វើអន្តរាគមន៍ ។

www.budinst.gov.kh www.elibraryofcambodia.org

# ជំពូកទី៣

# មេធាវី និងការជ្រើសរើសមេធាវី

## ផ្នែកទី១

## មេធាវី

មេធាវីប្រកបវិជ្ជាជីវៈឯករាជ្យ និងសេរីចូលរួមបំរើវិស័យយុត្តិធម៌ មេធាវីមិនស្ថិតនៅក្រោមឥទ្ធិពលកៀបសង្កត់នៃអំណាចណាមួយឡើយ ។ មេធាវីអាចតំណាងកូនក្តីតាមការយល់ព្រមពីកូនក្តី ឬជួយការពារកូនក្តីនៅគ្រប់សាលជំរះក្តី និងគ្រប់តំណាក់កាលនៃនីតិវិធីគ្រប់រឿងក្តីទាំងអស់ ជាពិសេសក្នុងរឿងរដ្ឋប្បវេណី ពាណិជ្ជកម្ម រដ្ឋបាល ការងារ សង្គមកិច្ច ។

ប៉ុន្តែក្នុងរឿងក្តីព្រហ្មទណ្ឌ មេធាវីជួយការពារកូនក្តីជាជនជាប់ចោទបាន តែមិនអាចធ្វើជាតំណាងបានទេ ។ មេធាវីអាចតំណាងអ្នកទទួលខុសត្រូវក្នុងបទរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងព្រហ្មទណ្ឌបាន ។

**សិទ្ធិរបស់មេធាវី**

១ - ការពារកូនក្តីរបស់ខ្លួនតាមផ្លូវច្បាប់
២ - ជំទាស់ការចោទប្រកាន់មកលើកូនក្តីរបស់ខ្លួន
៣ - បើជនសង្ស័យត្រូវបានតុលាការឃុំខ្លួនបណ្តោះអាសន្ន មេធាវីអាចដាក់ពាក្យសុំធានាជនសង្ស័យនោះឱ្យនៅក្រៅឃុំបណ្តោះអាសន្នបាន ។
៤ - មេធាវីដែលបានទទួលសិទ្ធិជាតំណាងពីដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី អាចចូលជំនួសកូនក្តីខ្លួនបាន នៅចំពោះមុខតុលាការ ។ ( មាត្រា១០៩ នីតិវិធីព្រហ្មទណ្ឌ ) ។
៥ - មេធាវីមានសិទ្ធិដោយសេរី ក្នុងការប្រាស្រ័យទាក់ទងជាមួយកូនក្តីខ្លួន ក្នុងពន្ធនាគារ ។ ( មាត្រា៨០ នីតិវិធីព្រហ្មទណ្ឌ ) ។

www.budinst.gov.kh www.elibraryofcambodia.org

៦ - មានសិទ្ធិចម្លងលិខិតទាំងឡាយនៃសំណុំរឿង ( មាត្រា១១០ នីតិវិធីព្រហ្មទណ្ឌ )

៧ - មេធាវីដែលទទួលសិទ្ធិគ្រប់បែបយ៉ាងពីដើមបណ្ដឹងរដ្ឋប្បវេណី មានសិទ្ធិប្ដឹងសុំអោយចៅក្រមឃុំខ្លួនជនជាប់ចោទ ដែលនៅក្រៅឃុំ ។ ( មាត្រា៩៥ នីតិវិធីព្រហ្មទណ្ឌ )។

មេធាវីអាចស្រាវជ្រាវការពិត ដើម្បីធ្វើអោយកូនក្ដីរបស់ខ្លួនរួចទោស ឬសំរាលទោសស្របតាមនីតិវិធី ត្រូវនិយាយការពារផលប្រយោជន៍អោយកូនក្ដីជានិច្ច អាចប្រមូលឯកសារដែលទាក់ទងនឹងរឿងក្ដី ។

តាមច្បាប់ស្ដីពីលក្ខនិកៈមេធាវី មេធាវីជាអ្នកផ្ដល់យោបល់ និងតាក់តែងលិខិតស្នាមគតិយុត្តិផ្សេងៗ ក្នុងវិស័យយុត្តិធម៌ ។ អាចបំពេញភារកិច្ចជាអ្នកផ្សះផ្សា សម្រុះសម្រួលតាមការចាត់តាំងរបស់គូក្ដី ឬចៅក្រមដែលបំពេញមុខងារ ។

**មាត្រា៤** : ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ក្រៅពីមេធាវីដែលជាសមាជិកនៃគណៈមេធាវី គ្មានជនណាម្នាក់អាចប្រកបមុខរបរយកកំរៃ ក្នុងការពិគ្រោះច្បាប់ ឬតាក់តែងលិខិតស្នាមគតិយុត្តិបានឡើយ លើកលែងតែការពិគ្រោះច្បាប់ ឬការតាក់តែងលិខិតស្នាមនោះជាការងារបន្ទាប់បន្សំនៃមុខងាររបស់ខ្លួន ឬជាមុខងារដែលច្បាប់បានអនុញ្ញាត ។

មេធាវីទាំងអស់សុទ្ធតែប្រកបវិជ្ជាជីវៈរបស់ខ្លួនដោយសេចក្ដីថ្លៃថ្នូរ ដោយសតិសម្បជញ្ញៈ ដោយសេចក្ដីទៀងត្រង់ ដោយមនុស្សធម៌ ដោយស្មារតីឯករាជ្យ និងដោយគោរពរដ្ឋធម្មនុញ្ញ និងច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ។ កិច្ចការដែលមេធាវីធ្វើឡើងសំរាប់អតិថិជន គ្មានជនណាម្នាក់អាចបង្ខំអោយបំពារបំពានលើការសំងាត់បានឡើយ នោះបីជានៅមុខតុលាការក៏ដោយ ។

បច្ចុប្បន្ននៅប្រទេសកម្ពុជាយើង ចំពោះមេធាវី ឬអ្នកការពារក្ដី ក៏ដូចជាអង្គការ សមាគមការពារសិទ្ធិមនុស្សដែរ ទាក់ទងនឹងរឿងក្ដីអាជ្ញា ( ព្រហ្មទណ្ឌ ) មានក្រុមប៉ូលិស និងពលរដ្ឋមួយចំនួនធំដែលយល់មិនទាន់ច្បាស់ ពួកគេតែងតែយល់ច្រឡំថា មេធាវីក្ដី អង្គការការពារសិទ្ធិមនុស្សក្ដី បង្កើតឡើងដើម្បីការពារជនទុច្ចរិត ប្រឆាំងនឹងគោលការណ៍ជាសារវ័ន្តរបស់សមត្ថកិច្ចប៉ូលិស ។ ការពិតពួកអ្នកការពារទូទៅតែងតែជួបប្រទះនូវផលវិបាកជាដរាប ព្រោះពួកគេខិតខំធ្វើការដើម្បីយុត្តិធម៌សង្គមពិតៗ ។ ជួនកាលមេធាវី ឬអ្នកការពារគេបានដឹងថា កូនក្ដីបានប្រព្រឹត្តបទល្មើសពិតៗ ប៉ុន្តែដោយតួនាទីភារកិច្ចរបស់គេត្រូវតែការពារផលប្រយោជន៍អោយកូនក្ដី តាំងពីដើមរហូតដល់ទីបំផុត ទើបគេនិយាយអះអាងក្នុងគោលបំណងអោយកូនក្ដីរួចខ្លួនពីបទចោទប្រកាន់ ជួនកាលកូនក្ដីទុច្ចរិតបានរួចខ្លួនពិតប្រាកដមែន ត្រង់ន័យនេះហើយដែលជាប្រការមិនសូវចូលចិត្តចំពោះមេធាវី ។ បញ្ហានេះគួរចាប់អារម្មណ៍ថា ជួនកាលបណ្ដាលមកពីអសមត្ថភាពក្នុងការប្រមូលភស្ដុតាងដាក់បន្ទុកទៅលើជនល្មើស ។

www.budinst.gov.kh www.elibraryofcambodia.org

ករណីនេះបានន័យថា វិមតិសង្ស័យទៅលើជនជាប់ចោទដែលអយ្យការ តែងតែលើកឡើងក្នុងលិខិតចោទប្រកាន់ គ្មានភស្តុតាងដែលអាចបញ្ជាក់បានថា ជនជាប់ចោទពិតជាជនល្មើស មូលហេតុនេះមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ចែងថា **"វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"** ឬភស្តុតាងទាំងនោះបានមកដោយការរំលោភបំពានទៅលើនីតិវិធីនៃច្បាប់ នេះជាមូលហេតុដែលនាំអោយជនជាប់ចោទ ឬជនត្រូវចោទរួចផុតពីការផ្តន្ទាទោសរបស់ច្បាប់ ស្របតាមច្បាប់រដ្ឋធម្មនុញ្ញ មាត្រា៣៨ ឆ្នាំ១៩៩៣ ចែងថា **"ការចោទប្រកាន់ ការចាប់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តបានត្រឹមត្រូវតាមបញ្ញត្តិច្បាប់"** និងស្របតាមមាត្រា២២ ច្បាប់ព្រហ្មទណ្ឌអន្តរកាលចែងថា **"ការមិនគោរពនីតិវិធីដែលចែងក្នុងមាត្រា១០ ទៅមាត្រា២១ នាំអោយដោះលែងជនជាប់ចោទអោយមានសេរីភាពជាបន្ទាន់"** ការប្រគល់សេរីភាពជាបន្ទាន់នេះអាចធ្វើឡើងតាមសេចក្តីសុំរបស់ទីប្រឹក្សានៃជនជាប់ចោទ ផ្នែករដ្ឋបាលស៊ីវិល ផ្នែកសិទ្ធិមនុស្ស ។ល។ ការរំលោភបំពានទៅលើនីតិវិធីនៃច្បាប់ មិនត្រឹមតែជាមូលហេតុដែលនាំអោយជនល្មើសរួចខ្លួនប៉ុណ្ណោះទេ ជួនកាលអាចនាំអោយអ្នកធ្វើខុសនីតិវិធីត្រូវទទួលទោសតាមច្បាប់ផងក៏មាន ។

ប៉ុន្តែជនត្រូវជាប់ចោទខ្លះគ្មាមិនបានប្រព្រឹត្តល្មើសទេ តែគ្នាត្រូវចោទដោយអយុត្តិធម៌ទៅវិញនេះក៏ជាប្រការដែលមេធាវី ឬអ្នកការពារផ្សេងៗត្រូវប្រឹងប្រែងជួយជនត្រូវចោទដែរ ។ ទោះជាយ៉ាងណាក៏ដោយ មេធាវីត្រូវតែបំពេញមុខងារតាមវិជ្ជាជីវៈរបស់ខ្លួន ដោយត្រូវលើកហេតុផលតាមផ្លូវច្បាប់ បង្ហាញភស្តុតាង និងរំលឹកអត្ថបទច្បាប់ផ្សេងៗជូនចៅក្រម ប្រយោជន៍ការពារកូនក្តីរបស់ខ្លួន ។ ប៉ុន្តែពុំមានសិទ្ធិសំរេចទេ គឺមានតែចៅក្រមទេ ជាអ្នកសំរេចថាខុស ឬត្រូវនោះ ។ បានសេចក្តីថា ក្នុងករណីណាក៏ដោយ មេធាវីពុំមានកំហុសតាមផ្លូវច្បាប់ ក្នុងការបញ្ចេញយោបល់ការពារកូនក្តីខ្លួនឡើយ ។

## ផ្នែកទី២

# ការជ្រើសរើសមេធាវី

ជនគ្រប់រូបមានសិទ្ធិស្វែងរកមេធាវី ឬស្នាក្តីអោយជួយការពារផលប្រយោជន៍របស់ខ្លួន ឬអោយធ្វើជាតំណាងរបស់ខ្លួនបាននៅគ្រប់តំណាក់កាលនៃនីតិវិធីក្នុងរឿងក្តីផ្សេងៗ លើកលែងតែរឿងក្តីព្រហ្មទណ្ឌ ដែលច្បាប់ហាមមិនអោយមេធាវីធ្វើជាតំណាង ។

ក្នុងរឿងក្តីព្រហ្មទណ្ឌភាគច្រើន មេធាវីរបស់ជនជាប់ចោទ គឺជាអ្នកជំទាស់ក្នុងការចោទប្រកាន់របស់ព្រះរាជអាជ្ញា ( តំណាងអយ្យការ ) ហើយច្បាប់បានទុកសិទ្ធិអោយជនជាប់ចោទរាល់រូបជ្រើសរើសរកមេធាវី ឬអ្នកការពារអោយជួយនិយាយការពារសិទ្ធិរបស់ខ្លួនបានដោយសេរី បើសិនជាមានលទ្ធ

www.budinst.gov.kh www.elibraryofcambodia.org

ភាពអាចរកដោយខ្លួនឯងបាន តែបើជនជាប់ចោទគ្មានលទ្ធភាពទេ រដ្ឋត្រូវចេញថ្លៃ ឬរកមេធាវីអោយជនត្រូវចោទតាមផ្លូវច្បាប់ ។

- អាជ្ញាធរមានសមត្ថកិច្ចត្រូវធានាថា ជនគ្រប់រូបដែលត្រូវបានឃាត់ខ្លួន ឬឃុំខ្លួនដោយការចោទប្រកាន់ ត្រូវតែផ្តល់លទ្ធភាពរកមេធាវី ឬស្មាក្តីក្នុងរយៈពេលមិនលើសពី៤៨ ម៉ោងក្រោយពីពេលឃុំខ្លួន ឬឃាត់ខ្លួននោះ ។

- ជនដែលជាប់ពន្ធនាគារ ជាប់ឃុំឃាំង ឬក៏ត្រូវឃាត់ខ្លួនត្រូវតែបានទទួលការអនុញ្ញាតអោយមានពេលវេលាល្អសមគួរ ដើម្បីប្រាស្រ័យទាក់ទងជាមួយមេធាវី ឬអ្នកការពាររបស់គេដោយផ្ទាល់ ក្នុងកន្លែងមួយសមរម្យ ។ ការសន្ទនារវាងជនជាប់ឃុំឃាំង ឬជនជាប់ចោទជាមួយនឹងមេធាវី ឬអ្នកការពារមិនត្រូវមានការលួចស្តាប់ លួចថតសម្លេង ឬលួចកត់ត្រាពីសំណាក់ជនណាម្នាក់ឡើយ ។

- មេធាវី ឬអ្នកការពារក្តីត្រូវបានច្បាប់អនុញ្ញាតអោយប្រកបវិជ្ជាជីវៈរបស់ខ្លួន ដោយមិនត្រូវមានការបំភិតបំភ័យ បន្ទុចបង្អាក់ វាយប្រហារ ឬអន្តរាគមន៍មិនសមស្របឡើយ ។

- មេធាវី ឬអ្នកការពារក្តី ឬអ្នកតំណាងអោយកូនក្តី មិនត្រូវមានទោសដោយសារតែការអនុវត្តន៍សកម្មភាពណាមួយ ដែលសមស្របតាមភារកិច្ច ឬក្រឹត្យក្រមវិជ្ជាជីវៈរបស់ខ្លួនទេ ។

- សព្វថ្ងៃនេះ មេធាវីមានពីរប្រភេទ គឺ ៖

## ១ - មេធាវីស្ម័គ្រចិត្តការពារជនក្រីក្រ

មេធាវីស្ម័គ្រចិត្ត ជាមេធាវីដែលទទួលប្រាក់កំរៃការងារពីបេឡាពិសេសនៃមូលនិធិនៃគណៈមេធាវី ប្រាក់បេឡាពិសេសសំរាប់ផ្តល់អោយមេធាវីស្ម័គ្រចិត្តការពារជនក្រីក្របានមកពីអំណោយ ឬជំនួយដែលឯកជន អង្គការអន្តរជាតិ ឬរដ្ឋាភិបាលនៃប្រទេសផ្សេងៗផ្តល់មកអោយ ។ មេធាវីស្ម័គ្រចិត្តមិនយកកំរៃពីកូនក្តី ឬជនដែលខ្លួនការពារក្តីអោយនោះទេ ។ សព្វថ្ងៃប្រទេសកម្ពុជាយើងមានអង្គការមេធាវីស្ម័គ្រចិត្តបីកន្លែង គឺនាយកដ្ឋានមេធាវីស្ម័គ្រចិត្តរបស់គណៈមេធាវី អង្គការគំរោងអ្នកការពារក្តីកម្ពុជា និងជំនួយផ្នែកច្បាប់នៃកម្ពុជា ដែលសហការជាមួយគណៈមេធាវី ។ មេធាវីស្ម័គ្រចិត្តបំពេញភារកិច្ចដូចគ្នានឹងមេធាវីឯកជន ។

www.budinst.gov.kh www.elibraryofcambodia.org

២ - មេធាវីឯកជន

មេធាវីឯកជន ជាមេធាវីដែលបើកការិយាល័យប្រកបវិជ្ជាជីវៈដោយខ្លួនរបស់គេផ្ទាល់ មេធាវីឯកជនរកប្រាក់កំរៃការងារដោយខ្លួនឯង ពុំមានប្រាក់បំណាច់ទេ ប្រាក់ដែលបានសំរាប់បំពេញភារកិច្ចគឺអាស្រ័យលើការព្រមព្រៀងគ្នារវាងមេធាវី និងអតិថិជនរបស់ខ្លួន ។ មេធាវីឯកជន និងមេធាវីស្ម័គ្រចិត្តបំពេញភារកិច្ចការពារផលប្រយោជន៍កូនក្តីដូចៗគ្នា ។ មេធាវីគ្រប់រូបមានកាតព្វកិច្ចជួយការពារជនក្រីក្រ ទាំងមេធាវីស្ម័គ្រចិត្តនៅក្នុងក្រុមមេធាវីស្ម័គ្រចិត្តការពារជនក្រីក្រ ទាំងមេធាវីប្រកបវិជ្ជាជីវៈតាមការិយាល័យឯកជន ។

ជនគ្រប់រូប ដែលមានបញ្ហាខាងផ្លូវច្បាប់ អាចស្វែងរកមេធាវីអោយជួយការពារផលប្រយោជន៍របស់ខ្លួនបាន តាមរយៈគណៈមេធាវី តុលាការ អង្គការសិទ្ធិមនុស្ស ឬមេធាវីផ្ទាល់ ។

## ជំពូកទី៤

## បណ្តឹង

បណ្តឹង គឺជាអំណាចមួយដែលច្បាប់ទទួលស្គាល់សំរាប់បុគ្គល ឬនីតិបុគ្គលដែលប្តឹងទៅតុលាការដើម្បីទាមទារអោយមានការគោរពសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់គេ ។

ចំពោះបណ្តឹងរដ្ឋប្បវេណី យោងទៅតាមសិទ្ធិដែលមានទៅលើចលនវត្ថុ ឬអចលនវត្ថុ ឬលើរូបបុគ្គលដែលជាគោលបំណងនៃការប្តឹង ដូចជា ដី ផ្ទះ កង់ ឡាន ម៉ូតូ ឬប្តឹងសុំអោយអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យាជាដើម ។

បុគ្គលអ្នកប្តឹង ត្រូវធ្វើបណ្តឹងដាក់ជូនទៅប្រធានតុលាការរដ្ឋប្បវេណី អោយបានទាន់ពេលវេលា កាលបើធ្វើឡើងក្រោយរយៈពេលច្បាប់កំណត់ បណ្តឹងនោះមិនអាចទទួលបានឡើយ ។

ចំពោះបណ្តឹងព្រហ្មទណ្ឌ យោងទៅតាមហេតុការណ៍ និងអន្តរាយដែលកើតមានឡើង ហើយដែលប៉ះពាល់ដល់អាយុជីវិត រូបរាងកាយ ទ្រព្យសម្បត្តិ សេចក្តីថ្លៃថ្នូរ ឬសណ្តាប់ធ្នាប់សាធារណៈ ។

បុគ្គលអ្នកប្តឹងត្រូវប្តឹងអោយចំជនល្មើស អាចសុំអោយមានការផ្តន្ទាទោសជនល្មើស និងសុំអោយជននោះបង់ប្រាក់សងការខូចខាត ឬអាចទាមទារប្រាក់ជំងឺចិត្តបាន ។

www.budinst.gov.kh www.elibraryofcambodia.org

# ផ្នែកទី១

# បណ្តឹងលើកដំបូង

**ទម្រង់នៃពាក្យបណ្តឹង**

ពាក្យបណ្តឹង គឺជាពាក្យពេចន៍និយាយលាតត្រដាង អំពីគោលបំណងនៃការប្តឹងសុំ ។ បណ្តឹងអាចធ្វើផ្ទាល់មាត់នៅចំពោះមុខមន្ត្រីមានសមត្ថកិច្ចក៏បាន អាចធ្វើបានជាលិខិតលាយលក្ខអក្សរដាក់ជូនមន្ត្រីមានសមត្ថកិច្ចក៏បាន ប៉ុន្តែជាគោលការណ៍ដើមបណ្តឹងត្រូវសរសេរពាក្យបណ្តឹងជាលាយលក្ខអក្សរ ដែលត្រូវបញ្ជាក់អោយបានច្បាស់លាស់ អំពី ៖

**ក - រូបវ័ន្តបុគ្គល**

- ឈ្មោះអ្នកប្តឹង ( ឈ្មោះក្នុងបញ្ជីជាតិ និងឈ្មោះហៅក្រៅ )
- ភេទ អាយុ ឬឆ្នាំកំណើត
- សញ្ជាតិ
- មុខរបរ
- ទីលំនៅដើមបណ្តឹង
- ឈ្មោះ អាសយដ្ឋានចុងចំលើយ និងពត៌មានផ្សេងៗទៀត ដែលអាចបញ្ជាក់បានអំពីភិនភាគរបស់ចុងចម្លើយ ។

**ខ - នីតិបុគ្គល**

- ត្រូវចុះនាមករណ៍
- ទីស្នាក់ការបំពេញការងារ ( ផ្ទះលេខ.............ផ្លូវ )
- អត្តសញ្ញាណពេញលេញរបស់តំណាង
- ពត៌មានសំខាន់សំរាប់កំណត់ភិនភាគចុងចម្លើយអោយបានត្រឹមត្រូវ ។

**កម្មវត្ថុបណ្តឹង**

កម្មវត្ថុត្រូវកំណត់អោយបានច្បាស់លាស់បំផុត ចំពោះបណ្តឹងរដ្ឋប្បវេណី តើប្តឹងទាមទារអ្វី ? ចំពោះបណ្តឹងព្រហ្មទណ្ឌ តើប្តឹងពីបុគ្គលណា ? ពីបទល្មើសអ្វី ?

www.budinst.gov.kh www.elibraryofcambodia.org

កម្មវត្ថុបណ្តឹងត្រូវអោយស្របច្បាប់ ស្របប្រពៃណី ហើយមិនត្រូវជាកម្មវត្ថុបណ្តឹង ដែលត្រូវបានតុលាការជំនុំជំរះជាស្ថាពររួចហើយឡើយ ។

**អធិប្បាយ**

បណ្តឹងត្រូវអធិប្បាយអំពីអង្គហេតុ និងមូលហេតុនៃទំនាស់ដោយសង្ខេប ដើម្បីអោយងាយយល់ព្រមទាំងត្រូវចង្អុលអំពីភស្តុតាង ឬឯកសារនានាដែលជាបង្អែកនៃការប្តឹង ។

**សំណូមពរនៃបណ្តឹង**

**បណ្តឹងព្រហ្មទណ្ឌ**

- អាចសុំអោយផ្តន្ទាទោសជនល្មើស និងគូកន
- អាចទាមទារសំណងការអន្តរាយ
- អាចទាមទារសំណងជំងឺចិត្ត
- អាចទាមទារថ្លៃខាតបង់ពេលវេលាប្រកបការងារ

**បណ្តឹងរដ្ឋប្បវេណី**

- អាចទាមទារអ្វីដែលយើងប្តឹងសុំ ( វត្ថុ ប្រាក់ ដីធ្លី ផ្ទះ.......)
- អាចសុំសំណងផ្សេងៗ
- អាចសុំអោយដាក់គុកបង្ខំលើរូបកាយបុគ្គល ដើម្បីទាមទារប្រាក់ធនទណ្ឌ

**បញ្ចប់បណ្តឹង**

ចុងបញ្ចប់នៃបណ្តឹង ត្រូវចេះប្រើពាក្យគួរសមដែលជាទីគោរពចំពោះអ្នកដែលទទួលចាត់ការបណ្តឹង ត្រូវចុះថ្ងៃ ខែ ឆ្នាំ និងចុះហត្ថលេខា ឬផ្តិតមេដៃស្តាំ បើសិនជាមានមេធាវី មេធាវីក៏ត្រូវចុះហត្ថលេខាទទួលដឹងឮដែរ ។

## កន្លែងដាក់ពាក្យបណ្តឹង

ជាគោលការណ៍ចំពោះពាក្យបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់ជូនទៅប្រធានតុលាការរដ្ឋប្បវេណីដោយផ្ទាល់ ឬនៅការិយាល័យនាយកក្រឡាបញ្ជីតុលាការ ។

www.budinst.gov.kh www.elibraryofcambodia.org

ចំពោះពាក្យបណ្តឹងព្រហ្មទណ្ឌ តាមធម្មតាពាក្យបណ្តឹងច្រើនចេញពីភាគីបុគ្គលរងគ្រោះ តែធាតុពិតបុគ្គលអ្នកធ្វើពាក្យបណ្តឹងមិនមែនជាដើមបណ្តឹងអាជ្ញាទេ គ្រាន់តែជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីព្រហ្មទណ្ឌតែប៉ុណ្ណោះ ។ មានតែព្រះរាជអាជ្ញាទេ ដែលជាដើមបណ្តឹងអាជ្ញា ដូច្នេះបណ្តឹងព្រហ្មទណ្ឌមានបណ្តឹងរដ្ឋប្បវេណីនៅក្នុងនោះ ឬក៏គ្មាន អាស្រ័យលើបុគ្គលអ្នកប្តឹង ។ បណ្តឹងទាំងពីរនេះ អាចធ្វើជាមួយគ្នាក៏បាន ធ្វើដោយឡែកពីគ្នាក៏បាន ។ ពាក្យបណ្តឹងព្រហ្មទណ្ឌ ត្រូវដាក់ជូនទៅព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង ឬនៅការិយាល័យនាយកក្រឡាបញ្ជីអយ្យការ បើពាក្យបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់ជូនប្រធានតុលាការរដ្ឋប្បវេណី ។

## ពាក្យបណ្តឹងបន្ថែម

ដើមបណ្តឹងអាចដាក់ពាក្យបណ្តឹងបន្ថែមលើពាក្យបណ្តឹងដើមបានរហូត កាលបើតុលាការពុំទាន់បានថយទៅពិភាក្សានៅពេលជំនុំជំរះ ។ បណ្តឹងបន្ថែមនេះ អាចធ្វើជាលាយល័ក្ខអក្សរ ឬអាចធ្វើផ្ទាល់មាត់បានក្នុងពេលបើកការជំនុំជំរះ ។ ក្នុងករណីនេះ ក្រឡាបញ្ជីសវនាការត្រូវកត់ត្រាសៀវភៅកំណត់ហេតុជំនុំជំរះ ដោយអោយដើមបណ្តឹងបន្ថែមនេះ ចុះហត្ថលេខា ឬផ្តិតមេដៃស្តាំក្នុងសៀវភៅកំណត់ហេតុនោះ ។ ឯបណ្តឹងបន្ថែមជាលាយល័ក្ខអក្សរ ក្រឡាបញ្ជីត្រូវចុះថ្ងៃ ខែ ឆ្នាំ និងចុះហត្ថលេខានៅរឹមបណ្តឹងនោះ ហើយចេញបង្កាន់ដៃទទួលទុកជាភស្តុតាងផង ។

## អំពីឯកសារនានា

ឯកសារនានាដែលមានប្រយោជន៍ទាក់ទងនឹងរឿងក្តី អាចភ្ជាប់ជាមួយបណ្តឹងដែលដាក់ជូនប្រធានតុលាការលើកដំបូងក៏បាន ឬនៅពេលដែលចៅក្រមអោយជូនសំអាងក្នុងតំណាក់កាលស៊ើបអង្កេតក៏បាន ។

## បណ្តឹងការពាររបស់ចុងចម្លើយ

ចុងចម្លើយអាចឆ្លើយតបនឹងបណ្តឹងរបស់ដើមចោទបានតាមគ្រប់មធ្យោបាយ ដែលមានដូចជា ៖

- លើកមតិប្រឆាំងតាមលិខិតជាលាយល័ក្ខអក្សរដាក់ជូនតុលាការ ឬតាមការឆ្លើយបំភ្លឺ ក្នុងតំណាក់កាលស៊ើបអង្កេតរបស់តុលាការក៏បាន ។

www.budinst.gov.kh www.elibraryofcambodia.org

- អាចសុំអោយតុលាការលើកពាក្យបណ្តឹងរបស់ដើមចោទ ដោយសំអាងមូលហេតុដើមចោទគ្មានគុណសម្បត្តិ ឬគ្មានផលប្រយោជន៍ក្នុងរឿង ឬរឿងផុតអាជ្ញាយុកាល ដែលច្បាប់បានកំណត់ ឬក៏លើកឡើងថា រឿងនេះមានសាលក្រមស្ថាពររួចម្តងហើយជាដើម ។ ប៉ុន្តែបញ្ហានេះ ចុងចម្លើយត្រូវលើកឡើងមុនពេលដែលតុលាការមិនទាន់ជំរះដល់អង្គសេចក្តី ។

# ការរលត់បណ្តឹង

**ចំពោះរឿងរដ្ឋប្បវេណី មូលហេតុដែលនាំអោយរលត់បណ្តឹងគឺ ៖**

- ផុតអាជ្ញាយុកាល
- ការស្រុះស្រួលគ្នា
- ការសង
- ការសំរេចសេចក្តីជាស្ថាពរ

**ចំពោះរឿងព្រហ្មទណ្ឌ មូលហេតុដែលនាំអោយរលត់បណ្តឹង គឺ ៖**

- ផុតអាជ្ញាយុកាល
- ជនល្មើសស្លាប់
- ការសំរេចសេចក្តីជាស្ថាពរ ។ល។

**គួរកត់សំគាល់ថា**

តាមគោលការណ៍បណ្តឹង ត្រូវដាក់ជូនតុលាការ ឬអយ្យការដោយផ្ទាល់ ប៉ុន្តែការដាក់ពាក្យបណ្តឹងមិនចាំបាច់តែម្ចាស់បណ្តឹងយកទៅដាក់នៅស្ថាប័នអយ្យការ ឬស្ថាប័នតុលាការផ្ទាល់តែម្តងទេ ពលរដ្ឋដែលមានទីលំនៅជិតស្ថាប័នទាំងពីរខាងលើនេះក្តី នៅឆ្ងាយក្តី អាចធ្វើពាក្យបណ្តឹងជូនទៅគ្រប់ស្ថាប័នដែលមានភារកិច្ចទទួលដោះស្រាយបណ្តឹង ដូចជា ដាក់ចូលទៅរដ្ឋអំណាចមូលដ្ឋាន ( ភូមិ ឃុំ ស្រុក ខេត្ត ) ស្ថាប័នប៉ូលិសយុត្តិធម៌ ឬអង្គការ សមាគមនានា ដើម្បីអោយគេជួយដោះស្រាយ និងជួយធ្វើអន្តរាគមន៍ទៅស្ថាប័នអយ្យការ ឬតុលាការ ឬស្ថាប័នមានសមត្ថកិច្ច ទទួលដោះស្រាយបណ្តឹង ។

www.budinst.gov.kh www.elibraryofcambodia.org

# ផ្នែកទី២

# គំរូពាក្យបណ្ដឹងផ្សេងៗ

៣៣៣៣

## ពាក្យបណ្ដឹង

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.............................................អាយុ..................ឆ្នាំ ជាតិ......................................................
មុខរបរ..............................ឃុំ........................................ស្រុក.......................................ខេត្ត............................ ។

## សូមគោរពចូលមក

លោក.............................................

**កម្មវត្ថុ** : សុំប្ដឹងទាមទារ ? ឬពីឈ្មោះ.....................................ភេទអាយុ..............ឆ្នាំ អាសយដ្ឋាន
........................ភូមិ....................ឃុំ......................ខេត្ត............................ ។
ពីបទ ".......................................... " ។

តាមវត្ថុខាងលើនេះ ខ្ញុំបាទ នាងខ្ញុំ សូមជំរាបជូនលោក.................................ជ្រាបដូចតទៅ ៖
( អធិប្បាយអង្គហេតុ និងមូលហេតុ ព្រមទាំងចង្អុលបង្ហាញអំពីភស្តុតាង ដែលជាបង្អែកនៃការប្ដឹង ) កាលពីថ្ងៃទី.................ខែ...............ឆ្នាំ...................................................................................
............................................................................................................................................
............................................................................................................................................

## សំណូមពរ

សុំអោយផ្ដន្ទាទោសតាមច្បាប់ និងសុំប្រាក់សំណងអន្តរាយ ប្រាក់ជំងឺចិត្តចំនួន.....................រៀល
............................................................................................................................................
............................................................................................................................................

អាស្រ័យហេតុនេះ សូមលោក...........................មេត្តាជួយស្វែងរកយុត្តិធម៌អោយដល់...........................ដោយអនុគ្រោះ ។

សូមលោក..................................ទទួលនូវសេចក្តីគោរពយ៉ាងជ្រាលជ្រៅអំពីខ្ញុំបាទ នាងខ្ញុំ ។

.............................................ថ្ងៃទី...................ខែ...............ឆ្នាំ..........................

ហត្ថលេខា ឬស្នាមមេដៃស្ដាំអ្នកប្ដឹង

ឈ្មោះ..................................

www.budinst.gov.kh www.elibraryofcambodia.org

# ករណីសិក្សា

*******

ប្រហែលជាពាក់កណ្ដាលអធ្រាត្រនៃយប់មួយ ក្នុងរដូវវស្សាមានភ្លៀងធ្លាក់យ៉ាងខ្លាំង មនុស្សម្នានៅក្នុងភូមិមួយ ដែលមានភ្លៀងធ្លាក់នោះ បានសម្រាន្តលង់លក់យ៉ាងស្កប់ស្កល់ ។ ពេលកំពុងភ្លៀងមានជនពីរនាក់ ក្នុងសំលៀកបំពាក់ជាទ័ពព្រៃឈរជើងនៅអង្គភាពវរៈ៤៤ បានគោះទ្វារផ្ទះប្រជាជនសុំជ្រកភ្លៀង គឺផ្ទះរបស់ឈ្មោះ **ផល្លី** និងប្ដីឈ្មោះ **សាខន** ជាជនពិការជើងម្ខាង ពេលភ្លៀងកំពុងធ្លាក់ជនទាំងពីរនាក់ត្រូវបានម្ចាស់ផ្ទះបើកទ្វារផ្ទះអោយចូលជ្រក ។ កំពុងជ្រកភ្លៀង ជនពីរនាក់នោះ បានសុំថ្នាំពីឈ្មោះ **សាខន** យកមកមូរជក់ ។ រយៈពេលកន្លះម៉ោងក្រោយមកភ្លៀងរាំង ជនទាំងនោះ ក៏បានលាម្ចាស់ផ្ទះចេញទៅបានមួយភ្លែត ក៏ត្រឡប់មកវិញចាប់ប្ដីដែលឈ្មោះ **សាខន** ចងទុកនៅក្នុងផ្ទះ ហើយចាប់ប្រពន្ធឈ្មោះ **ផល្លី** យកទៅដល់ព្រៃខាងក្រោយផ្ទះ ចំងាយប្រហែល១០០ម៉ែត្រ ក៏នាំគ្នារំលោភម្ដងម្នាក់ៗ បណ្ដាលអោយស្ត្រីឈ្មោះ **ផល្លី** រងរបួសជាទម្ងន់ រហូតទៅសំរាកព្យាបាលនៅមន្ទីរពេទ្យ ។

- តើអំពើរបស់ជនទាំងពីរនាក់ ជាអំពើល្មើសច្បាប់ដែរឬទេ ?
- តើជាអំពើល្មើសច្បាប់អ្វី ? ថ្នាក់ណា ?
- ក្នុងករណីសិក្សានេះ បើជនទាំងពីរជាទាហាន អំពើរបស់គេអាចជាអំពើរំលោភសិទ្ធិមនុស្សដែរឬទេ ?
- តើជនរងគ្រោះ ឬគ្រួសារជនរងគ្រោះអាចធ្វើអ្វីបានចំពោះជនទាំងពីររូបខាងលើ ?

**ចម្លើយនឹងត្រូវបានបកស្រាយជូនដូចមាន :**

នៅក្នុងគំរូពាក្យបណ្ដឹងបន្តបន្ទាប់ខាងមុខនេះ ៖

www.budinst.gov.kh www.elibraryofcambodia.org

**គំរូទី១**

# អំពីបទល្មើសខ្មែរក្រហមរំលោភសេពសន្ថវៈ

៚៚៚៚

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្តឹង

ខ្ញុំបាទឈ្មោះ................................អាយុ....................ឆ្នាំ ជាតិ.........................មុខរបរ..........................
ទីលំនៅភូមិ.............................ឃុំ............................ស្រុក...........................ខេត្ត........................ ។

**សូមគោរពជូន**

**លោកមេភូមិ**...............................

ក្បិតខ្ញុំបាទកើតទុក្ខមិនសុខចិត្តនឹងទាហានពីរនាក់មិនស្គាល់ឈ្មោះ នៅអង្គភាពទ័ពព្រៃ ក្នុងឃុំរបស់យើង ដែលបានចាប់ប្រពន្ធរបស់ខ្ញុំយកទៅរំលោភសេពសន្ថវៈ នៅព្រៃខាងក្រោយផ្ទះរបស់ខ្ញុំបាទ ចំងាយ១០០ម៉ែត្រពីផ្ទះ កាលពីយប់មិញ គឺយប់ថ្ងៃទី.........ខែ.........ឆ្នាំ.........ម៉ោង............... ដោយដំបូងពួកវាទាំងពីរនាក់បានចូលមកសុំជ្រកភ្លៀងនៅផ្ទះរបស់ខ្ញុំបាទ ហើយបានសុំថ្នាំជក់មួយបារីម្នាក់ ។ ពេលរាំងភ្លៀង ពួកគេក៏លាខ្ញុំបាទចេញទៅ បន្តិចក្រោយមក ក៏ត្រឡប់មកវិញ ចាប់ខ្ញុំបាទចង ហើយឆ្លង់ប្រពន្ធខ្ញុំអោយទៅជាមួយពួកគេ ហើយក៏រំលោភសេពសន្ថវៈប្រពន្ធរបស់ខ្ញុំបាទ នៅក្រោយផ្ទះតែម្តង ពីរម៉ោងក្រោយមកទើបប្រពន្ធរបស់ខ្ញុំបាទត្រឡប់មកផ្ទះវិញ និយាយរឿងនេះប្រាប់ខ្ញុំបាទ ។

សូមលោកមេភូមិមេត្តាជួយធ្វើអន្តរាគមន៍ស្វែងរកយុត្តិធម៌អោយខ្ញុំបាទផង ។

.........................ថ្ងៃទី...............ខែ...............ឆ្នាំ...............

**ហត្ថលេខា ឬស្នាមមេដៃស្តាំអ្នកប្តឹង**

ឈ្មោះ...........................

www.budinst.gov.kh www.elibraryofcambodia.org

គំរូទី២

# អំពីបទល្មើសខុសក្រិដ្ឋរំលោភសេពសន្ថវៈមួយទៀត

៚៚៚៚

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្ដឹង

ខ្ញុំបាទឈ្មោះ.................................អាយុ....................ឆ្នាំ ជាតិ........................ មុខរបរ..........................
ទីលំនៅភូមិ...................................ឃុំ..............................ស្រុក........................ខេត្ត................................ ។

### សូមគោរពជូន

(1)............ព្រះរាជអាជ្ញាអមតុលាការ..............................

**កម្មវត្ថុ** : សុំប្ដឹងពីឈ្មោះ.............................ភេទ..........អាយុ...........ឆ្នាំ................ សញ្ជាតិ...................
មុខរបរ...........................ទីលំនៅភូមិ..............................ឃុំ.........................ស្រុក.........................
ខេត្ត...........................ពីបទ " រំលោភសេពសន្ថវៈ " ។

ដូចក្នុងកម្មវត្ថុខាងលើនេះ សូមព្រះរាជអាជ្ញាមេត្តាជ្រាបថា ៖

កាលពីថ្ងៃទី.............ខែ..................ឆ្នាំ..................ឈ្មោះ............................. ជាកូនប្រសា របស់នាងខ្ញុំបានបបួលប្អូនស្រីនាងខ្ញុំឈ្មោះ.......................................អាយុ.................ឆ្នាំ ជាជនពិការជើងទៅដើររកអុសនៅព្រៃឫស្សីមួយ ឃ្លាតពីផ្ទះរបស់នាងចំងាយ៥០ម៉ែត្រ ហើយបានចាប់រំលោភប្អូនស្រីរបស់នាងខ្ញុំ នៅវេលាម៉ោង...........................ក្នុងថ្ងៃទី ខែ ឆ្នាំខាងលើនេះ ។

ហេតុនេះ សូមព្រះរាជអាជ្ញា មេត្តាប្ដឹងចោទកូនប្រសាររបស់នាងខ្ញុំ ដែលមានឈ្មោះខាងលើនេះ ទៅផ្ដន្ទាទោសតាមច្បាប់ជាធរមាន ។

សូមលោកព្រះរាជអាជ្ញាទទួលនូវសេចក្ដីគោរពយ៉ាងជ្រាលជ្រៅអំពីនាងខ្ញុំ ។

ថ្ងៃទី...............ខែ...............ឆ្នាំ...............

ហត្ថលេខា ឬស្នាមមេដៃស្ដាំអ្នកប្ដឹង

ឈ្មោះ...........................

www.budinst.gov.kh www.elibraryofcambodia.org

គំរូទី៣

# អំពីបទល្មើសខុសក្រិដ្ឋរំលោភសេពសន្ថវៈមួយទៀត

៙៙៙៙

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្តឹង

ខ្ញុំបាទឈ្មោះ.......................... អាយុ.................ឆ្នាំ ជាតិ...................... មុខរបរ...........................
ទីលំនៅភូមិ.......................ឃុំ.......................ស្រុក......................ខេត្ត.............................។

**សូមគោរពជូន**

**ព្រះរាជអាជ្ញារអមតុលាការ..........................**

**កម្មវត្ថុ** : សុំប្តឹងពីឈ្មោះ............................ភេទ.............អាយុប្រហែល...........(1) និងម្នាក់ទៀតមិនស្គាល់ឈ្មោះ.........................អាយុប្រហែល.................(2) ជាទំពឈរជើងនៅ................. ពីបទ " រំលោភសេពសន្ថវៈ " ។

តាមកម្មវត្ថុខាងលើនេះ សូមលោកព្រះរាជអាជ្ញា មេត្តាជ្រាបនូវដំណើររឿងដូចតទៅ ៖

កាលពីថ្ងៃទី............. ខែ................ ឆ្នាំ.............. ចៅស្រីរបស់នាងខ្ញុំឈ្មោះ................................ អាយុ..........ឆ្នាំ និងប្អូនជីដូនមួយរបស់វាឈ្មោះ........................ភេទ..............អាយុ.......ឆ្នាំ បានចេញទៅឃ្វាលគោជាមួយក្មេងក្នុងភូមិជាច្រើនទៀតនៅខាងកើតភូមិ ។ ពេលនោះចៅស្រីរបស់នាងខ្ញុំ និងប្អូនជីដូនមួយរបស់វាបានចូលទៅរកកាច់ពោតនៅក្នុងចំការ ស្រាប់តែលេចមុខទាហានខាងលើចេញមកម្នាក់ចាប់ចៅស្រីរបស់នាងខ្ញុំខ្ទប់មាត់យកចូលទៅក្នុងព្រៃ ។ ម្នាក់ទៀតនៅក្តង់ប្អូនជីដូនមួយរបស់វាមិនអោយស្រែក ។ ម្នាក់ដែលចាប់ចៅស្រីរបស់នាងខ្ញុំយកទៅក្នុងព្រៃបានរំលោភសេពសន្ថវៈចៅស្រីនាងខ្ញុំរួចហើយក៏ស្រែកហៅឈ្មោះគ្នាគេ ដែលកំពង់ក្តង់ប្អូនជីដូនមួយវាអោយទៅរំលោភម្តង ទើបស្គាល់តែឈ្មោះជនល្មើសម្នាក់តែប៉ុណ្ណោះ ។

ដូចនេះ សូមព្រះរាជអាជ្ញាអមតុលាការ មេត្តាចាត់ការជនល្មើសទាំងពីរយកមកផ្តន្ទាទោសតាមច្បាប់ និងសុំអោយជនល្មើសទាំងពីរបង់ប្រាក់ជំងឺចិត្តចំនួន........................ រៀល ដោយអនុគ្រោះ ។

...................ថ្ងៃទី............. ខែ............. ឆ្នាំ...................

**ហត្ថលេខា ឬស្នាមមេដៃស្តាំអ្នកប្តឹង**

www.budinst.gov.kh www.elibraryofcambodia.org

ឈ្មោះ..................................

**គំរូទី៤**

# អំពីបទល្មើសឧក្រិដ្ឋមនុស្សឃាតគិតទុកជាមុន

៚៚៚៚

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្តឹង

ខ្ញុំបាទឈ្មោះ............................អាយុ...............ឆ្នាំ ជាតិ.......................មុខរបរ.............................
ទីលំនៅភូមិ............................ឃុំ.......................ស្រុក........................ខេត្ត.........................។

**សូមគោរពចូលមក**

ព្រះរាជអាជ្ញារអមតុលាការ...........................

**កម្មវត្ថុ** : សុំប្តឹងពីឈ្មោះ.........................ភេទ.............អាយុ.........ឆ្នាំ សញ្ជាតិ.........................
មុខរបរ.........................ទីលំនៅភូមិ.........................ឃុំ.....................ស្រុក.........................
ខេត្ត................ ឋានៈ.................ពីបទ " **សម្លាប់មនុស្ស** "។

តាមកម្មវត្ថុខាងលើនេះ ខ្ញុំសូមជំរាបជូនព្រះរាជអាជ្ញាជ្រាបដូចតទៅ ៖

កាលពីថ្ងៃទី..........ខែ............ឆ្នាំ..............វេលាម៉ោង៥ព្រឹក ខ្ញុំបាទបានភ្ញាក់ពីដំណេកចុះពីលើផ្ទះមកដី ដើរទៅបន្ទោរបង់នៅព្រៃខាងក្រោយផ្ទះ ស្រាប់តែជនខាងលើ ក្នុងឯកសណ្ឋានជាទាហានបានចេញពីគុម្ពោធព្រៃក្បែរខ្លួនរបស់ខ្ញុំបាទមកភ្ជង់ខ្ញុំបាទដោយគំរាមថា បើហ៊ានស្រែកអញបាញ់សម្លាប់ចោល ។ ពេលនោះម្នាក់នៅភ្ជង់ខ្ញុំបាទ ឯម្នាក់ទៀតដើរឡើងទៅលើផ្ទះរបស់ខ្ញុំបាទ រំពេចនោះ មានការផ្ទុះអាវុធពីរគ្រាប់នៅលើផ្ទះ រួចហើយជនទាំងពីរនោះ ក៏នាំគ្នារត់គេចខ្លួនទៅទិសខាងកើត ចូលទៅក្នុងព្រៃបាត់ទៅ ដោយពួកគេពុំធ្វើអ្វីដល់រូបខ្ញុំបាទទេ ហើយខ្ញុំបាទក៏រត់ឡើងមកលើផ្ទះ ស្រាប់តែឃើញកូនប្រុសរបស់ខ្ញុំបាទឈ្មោះ.........................បានដេកស្លាប់នៅលើផ្ទះ ត្រូវគ្រាប់កាំភ្លើងពីរគ្រាប់ត្រង់ក្បាល ។

ជនទាំងពីរនាក់ដូចមានឈ្មោះខាងលើ ខ្ញុំបាទមិនដែលស្គាល់ទេ ប៉ុន្តែសាក្សីឈ្មោះ..........ជាអ្នកប្រាប់ ព្រោះគេធ្លាប់ស្គាល់ជនទាំងពីរ និងបានឃើញសកម្មភាពរបស់ជនទាំងពីរនាក់នៅពេលកើតហេតុ ។

www.budinst.gov.kh www.elibraryofcambodia.org

ហេតុដូច្នេះ សូមលោកព្រះរាជអាជ្ញាមេត្តានាំខ្លួនជនល្មើសទាំងពីរនាក់យកមកផ្តន្ទាទោសតាមច្បាប់ និងបង្គាប់អោយសងប្រាក់ជំងឺចិត្តចំនួន.......................... រៀល មកខ្ញុំបាទដោយអនុគ្រោះ ។

សូមលោកព្រះរាជអាជ្ញាទទួលនូវសេចក្តីគោរពយ៉ាងជ្រាលជ្រៅអំពីខ្ញុំ ។

ថ្ងៃទី.............. ខែ............... ឆ្នាំ................

**ហត្ថលេខា ឬស្នាមមេដៃដើមបណ្តឹង**

ឈ្មោះ........................................

www.budinst.gov.kh www.elibraryofcambodia.org

**គំរូទី៥**

# អំពីបទល្មើសខូវក្រិដ្ឋមនុស្សឃាតគិតទុកជាមុន

៥៥៥៥

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្តឹង

ខ្ញុំបាទឈ្មោះ.............................អាយុ...................ឆ្នាំ ជាតិ...............................មុខរបរ.......................
ទីលំនៅភូមិ..............................ឃុំ...............................ស្រុក.............................ខេត្ត.............................។
.....................

**សូមគោរពជូន**

**លោកប្រធានសមាគមសិទ្ធិមនុស្ស**...........................

**កម្មវត្ថុ** : សុំប្តឹងពីឈ្មោះ...........................ភេទ.............អាយុ...........ឆ្នាំ សញ្ជាតិ............................ មុខរបរធ្វើអាជីវកម្មព្រៃឈើ ពីបទ " ប៉ុនប៉ងសម្លាប់រូបខ្ញុំ " ។

ត្បិតក្រោយពីកាសែត.........................លេខ..................... ចេញផ្សាយថ្ងៃទី.........ខែ...............ឆ្នាំ ................ រួចមកមានសាក្សីឈ្មោះ.................................... និងឈ្មោះ.................................... បានប្រាប់ខ្ញុំបាទថា ឈ្មោះខាងលើមានបំណងចង់សម្លាប់រូបខ្ញុំ ដោយសារតែខ្ញុំបាទសរសេរអត្ថបទកាសែតមួយច្បាប់ ក្រោមចំណងជើងថា "....................................." ដែលមានការប៉ះពាល់ដល់សកម្មភាពប្រកបអាជីវកម្មព្រៃឈើខុសច្បាប់របស់ពួកគេ បញ្ហានេះខ្ញុំបាទមានការព្រួយបារម្ភណាស់ ព្រោះឈ្មោះខាងលើកំពុងស្វែងរកខ្ញុំ ដើម្បីសម្លាប់ចោល ។

ហេតុនេះ សូមលោកប្រធានសមាគមមេត្តាជួយធ្វើអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ច ដើម្បីមានវិធានការទប់ស្កាត់ អំពើប៉ុនប៉ងរបស់ជនល្មើសដោយអនុគ្រោះផង ។

សូមលោកប្រធានមេត្តាទទួលនូវការគោរពយ៉ាងជ្រាលជ្រៅអំពីខ្ញុំបាទ ។

ភ្នំពេញ, ថ្ងៃទី.........ខែ...............ឆ្នាំ.........

**ហត្ថលេខា ឬស្នាមមេដៃស្តាំអ្នកប្តឹង**

**ឈ្មោះ**..............................

www.budinst.gov.kh www.elibraryofcambodia.org

**គំរូទី៦**

# អំពីបទល្មើសផ្ទាក់មជ្ឈមបង្ករបួសស្នាម

៚៚៚

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្តឹង

ខ្ញុំបាទឈ្មោះ.................អាយុ...........ឆ្នាំ ជាតិ.................មុខរបរ................ ទីលំនៅភូមិ...........................ឃុំ-សង្កាត់.......................ស្រុក-ខណ្ឌ......................ខេត្ត-ក្រុង................ ជាឪពុករបស់ជនរងគ្រោះឈ្មោះ.............................. ។

### សូមគោរពជូន

ព្រះរាជអាជ្ញាអមតុលាការខេត្ត.............................

**កម្មវត្ថុ** : សុំប្តឹងពីឈ្មោះ.........................ភេទ............អាយុ..........ឆ្នាំ សញ្ជាតិ........................ ទីលំនៅភូមិ..............................ឃុំ.......................ស្រុក..................ខេត្ត................. ពីបទ " **បង្ករបួសស្នាម** " លើកូនប្រុសរបស់ខ្ញុំបាទឈ្មោះ.......................... ។

ត្បិតកាលពីថ្ងៃទី............ខែ.............ឆ្នាំ.............. វេលាម៉ោង.......... នៅលើផ្លូវរទេះខាងមុខផ្ទះរបស់ខ្ញុំបាទ ចំងាយ៣ម៉ែត្រ ឈ្មោះ..........................ដើរមកចាក់កូនរបស់ខ្ញុំបាទឈ្មោះ................... មួយកាំបិតជំពុះទុងកាំភ្លើង ដោយគ្មានមូលហេតុបណ្តាលអោយរងរបួសត្រង់ឆ្អឹងជំនីក្រោមដោះខាងឆ្វេង រួចហើយជនល្មើសក៏រត់គេចខ្លួនបាត់ ដោយនាំយកផ្លែកាំបិតជំពុះទុងនោះទៅជាមួយផង ។

សកម្មភាពមុនពេលកើតហេតុ កូនរបស់ខ្ញុំបាទឈ្មោះ....................បានអង្គុយផឹកស្រានៅមុខផ្ទះជាមួយឈ្មោះ.........................(១)ឈ្មោះ.........................(២)ឈ្មោះ..............................(៣) និងអ្នកផ្សេងៗទៀត ដែលមិនចាំឈ្មោះចាប់តាំងពីម៉ោង១២ថ្ងៃត្រង់ រហូតដល់ម៉ោង៣រសៀល ឈ្មោះ.............................បានតៀកកូនរបស់ខ្ញុំបាទ ដើរមកផ្លូវរទេះខាងមុខផ្ទះ ស្រាប់តែជនល្មើសឈ្មោះ.............................ដើរមកពីទិសខាងត្បូងលើកកាំបិតចាក់កូនរបស់ខ្ញុំបាទតែម្តង ពេលនោះមានឈ្មោះ...........................និងឈ្មោះ.............................. ជាអ្នកចូលរួមផឹកស្រាបានឃើញច្បាស់ ។

www.budinst.gov.kh www.elibraryofcambodia.org

នៅពេលកូនរបស់ខ្ញុំបាទមានរបួសឈ្មោះ....................................... និងអ្នកផឹកស្រាជាមួយគ្នាបានយកទៅមន្ទីរពេទ្យ.................................សំរាកព្យាបាលរយៈពេល១០ថ្ងៃ ទើបចេញពីមន្ទីរពេទ្យមកព្យាបាលបន្តនៅផ្ទះអស់ទឹកប្រាក់សរុបចំនួន៦០០.០០០រៀល ( ហុកសិបម៉ឺនរៀល ) ។

បញ្ហានេះ ខ្ញុំបាទបានប្តឹងទៅនគរបាលស្រុក..........................តាំងពីក្រោយពេលកើតហេតុភ្លាមៗមកម្ល៉េះ ហើយនគរបាលបានហៅខ្ញុំបាទ និងឪពុកម្តាយរបស់ជនល្មើសទៅធ្វើការផ្សះផ្សាម្តង ប៉ុន្តែមិនបានលទ្ធផល ដោយសារខ្ញុំបាទទាមទារសំណងចំនួន១.៥០០.០០០រៀល ( មួយរយហាសិបម៉ឺនរៀល ) គេព្រមបង់អោយត្រឹមតែ១០០.០០០រៀល ( ដប់ម៉ឺនរៀល ) តែប៉ុណ្ណោះ ។

ហេតុនេះ ខ្ញុំបាទសូមគោរពចូលមកលោកព្រះរាជអាជ្ញា ដើម្បីរកយុត្តិធម៌តាមសំណូមពរដូចខាងក្រោម ៖

១ - សុំផ្តន្ទាទោសជនល្មើសតាមច្បាប់

២ - សុំទាមទារប្រាក់ចំនួន១.៥០០.០០០រៀល ( មួយរយហាសិបម៉ឺនរៀល ) ដោយគិតទៅលើ ។

- ថ្លៃព្យាបាលចំនួន៦០០.០០០រៀល ( ហុកសិបម៉ឺនរៀល )
- ប្រាក់ជំងឺចិត្តចំនួន៥០០.០០០រៀល ( ហាសិបម៉ឺនរៀល )
- ថ្លៃខាតបង់ពេលវេលារកស៊ី និងចំណាយផ្សេងៗចំនួន៤០០.០០០រៀល ( សែសិបម៉ឺនរៀល ) ។

សូមលោកមេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ។

ធ្វើនៅ................ ថ្ងៃទី........... ខែ............... ឆ្នាំ....................

ស្នាមមេដៃស្តាំអ្នកប្តឹង

ឈ្មោះ...........................

BUDDHIST INSTITUTE LIBRARY

www.budinst.gov.kh www.elibraryofcambodia.org

**គំរូទី៧**

# អំពីបទល្មើសសម្លាប់មនុស្ស និងបង្ករបួសស្នាមដោយចេតនា

## ពាក្យបណ្តឹង

ខ្ញុំបាទឈ្មោះ...............................អាយុ...................ឆ្នាំ ជាតិ.......................មុខរបរ...........................
ទីលំនៅភូមិ...............................ឃុំ........................ស្រុក........................ខេត្ត...................... ។

## សូមគោរពជូន

**ព្រះរាជអាជ្ញាអមតុលាការខេត្ត..............................**

**កម្មវត្ថុ** : សុំប្តឹងពីអ្នកបើករថយន្តម្នាក់មិនទាន់ស្គាល់ឈ្មោះ ។

សេចក្តីដូចមានក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមជំរាបជូនព្រះរាជអាជ្ញាជ្រាបនូវដំណើររឿងហេតុដូចខាងក្រោមនេះ ៖

កាលពីថ្ងៃទី...............ខែ.................ឆ្នាំ.............វេលាម៉ោង៥ល្ងាច នៅពេលដែលខ្ញុំបាទកំពុងជិះម៉ូតូមួយគ្រឿងម៉ាក....................តាមបណ្តោយផ្លូវជាតិលេខ..................ឆ្ពោះទៅទិសខាងលិច មកដល់ត្រង់ចំណុចផ្លូវបត់ចូលដេប៉ូខ្សាច់ ភូមិ...............ឃុំ..............ស្រុក.............ខេត្ត.................. ស្រាប់តែមានរថយន្តបែនពណ៌លឿងម៉ាក................មួយគ្រឿង ពាក់ផ្លាកលេខ...................បើកមកពីក្រោយស្របទិសតែមួយ ហើយបរជែងម៉ូតូរបស់ខ្ញុំបាទដោយកាច់ចង្កូតមកខាងស្តាំ កាត់មុខម៉ូតូរបស់ខ្ញុំបាទៗនឹកស្មានថា រថយន្តនោះអែបស្តាំ ខ្ញុំបាទក៏ងាកមកឆ្វេង ការពិតរថយន្តគ្រាន់តែងាកស្តាំកាត់មុខម៉ូតូ ដើម្បីយកស្ថានភាពហើយក៏បត់ឆ្វេង ។ មួយរំពេចភ្លាមនោះ ខ្ញុំបាទក៏ងាកចង្កូតម៉ូតូបញ្ចៀសកុំអោយបុករថយន្ត តែរថយន្តចេះតែកៀរខ្ញុំរហូតដល់ផ្លូវចុះពីថ្នល់ជាតិ ហើយក៏ទង្គិចដៃម៉ូតូរបស់ខ្ញុំបាទ បណ្តាលឱ្យម៉ូតូដួល ហើយបណ្តាលអោយកូនរបស់ខ្ញុំបាទធ្លាក់ស្លាប់នៅនឹងកន្លែងកើតហេតុ ។

បន្ទាប់ពីគ្រោះថ្នាក់កើតឡើង អ្នកបើកបរបានឈប់រថយន្ត ហើយរត់គេចខ្លួនទៅទិសខាងត្បូង ដោយមានអោបកូនម្នាក់អាយុប្រហាក់ប្រហែលនឹងកូនរបស់ខ្ញុំបាទដែរ ពេលកំពុងរត់ ខ្ញុំបាទបានបក់ដៃហៅជននោះអោយត្រឡប់ក្រោយវិញ ដើម្បីជួយយកកូនរបស់ខ្ញុំបាទទៅមន្ទីរពេទ្យ ប៉ុន្តែគេគ្រាន់តែងាកមកក្រោយ តែមិនត្រឡប់ក្រោយចេះតែរត់ដោយមិនរវល់អ្វីទាំងអស់ ។

ក្រោយពេលកើតហេតុ នគរបាលចរាចរស្រុកបានធ្វើកិច្ចការនោះ ដោយនាំយកទាំងរថយន្ត និងម៉ូតូរបស់ខ្ញុំបាទទៅទុកនៅផ្នែកចរាចរស្រុក ដើម្បីធ្វើការដោះស្រាយដោយកំណត់ពេលផ្សះផ្សាចំនួន

www.budinst.gov.kh www.elibraryofcambodia.org

៤លើក តែបានធ្វើការតែពីរលើកទេ គឺ ៖

**លើកទី១** : ថ្ងៃទី.......... ខែ................ ឆ្នាំ.............. ថៅកែក្រុមហ៊ុនមិនទាន់ស្គាល់ឈ្មោះដែលទទួលខុសត្រូវលើរថយន្តបានចាត់តំណាងម្នាក់មកជួបចរចាជាមួយខ្ញុំបាទ នៅការិយាល័យចរាចរស្រុកមិនបានលទ្ធផល ដោយខ្ញុំទាមទារសំណងចំនួន៧០០០ដុល្លារ គេសុំសង៥០០ដុល្លារ ។

**លើកទី២** : ថ្ងៃទី............ ខែ................ ឆ្នាំ............ តំណាងមកជូនដំណឹងថា ថៅកែត្រូវចូលមកដោះស្រាយផ្ទាល់ ប៉ុន្តែដោយគាត់កំពុងមានជំងឺ គាត់សុំពន្យារពេលសិន ។

**លើកទី៣** : ថ្ងៃទី.............. ខែ................ ឆ្នាំ............ ថៅកែចូលទៅចរចាសុំសង២.០០០.០០០រៀល ខ្ញុំបាទសុខចិត្តចុះមកនៅត្រឹម៣.៥០០ដុល្លារ ។

ដោយការដោះស្រាយនៅចរាចរស្រុកពុំទទួលបានលទ្ធផល ហើយចេះតែអូសបន្លាយពេលវេលានោះ ខ្ញុំបាទសូមគោរពចូលមកព្រះរាជអាជ្ញាសុំមេត្តាជួយធ្វើការដោះស្រាយវិញ ដោយខ្ញុំបាទមានសំណូមពរ :

១ - សុំស្វែងរកអ្នកបើកបររថយន្តមកធ្វើការចោទប្រកាន់ និងផ្តន្ទាទោសតាមច្បាប់

២ - សុំទាមទារសំណង ដោយគ្មានការកែប្រែនូវចំនួនទឹកប្រាក់សរុប៣.៥០០ដុល្លារ ដោយគិតទៅលើចំណាយធ្វើបុណ្យសពតាមប្រពៃណីចំនួន១.២០០ដុល្លារ ចំណាយព្យាបាលជំងឺ និងជួសជុលម៉ូតូចំនួន១.១០០ដុល្លារ និងសំណងជំងឺចិត្តចំនួន១.២០០ដុល្លារ ក្បិតមួយជីវិតប្តី ប្រពន្ធរបស់ខ្ញុំបាទមានកូនតែម្នាក់ ហើយត្រូវបាត់បង់ទៅវិញ ធ្វើអោយយើងខ្ញុំជាឪពុក ម្តាយពិបាកចិត្ត រហូតធ្លាក់ខ្លួនឈឺមិនអាចប្រកបកិច្ចការរកស៊ីអ្វីបានឡើយ ។

អាស្រ័យហេតុនេះ សូមលោកព្រះរាជអាជ្ញា មេត្តាជួយដោះស្រាយតាមសំណូមពររបស់ខ្ញុំបាទដោយអនុគ្រោះ ។

សូមលោកព្រះរាជអាជ្ញា មេត្តាទទួលនូវការគោរព និងអំណរគុណយ៉ាងជ្រាលជ្រៅអំពីខ្ញុំបាទ ។

ធ្វើនៅ.................. ថ្ងៃទី............ ខែ.......... ឆ្នាំ..................

**ស្នាមមេដៃ**

ឈ្មោះ..............................

www.budinst.gov.kh www.elibraryofcambodia.org

គំរូទី៨

# ប្តឹងសុំលែងលះប្តី ប្រពន្ធ

៥៥៥៥

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យបណ្តឹង

នាងខ្ញុំឈ្មោះ.......................... អាយុ.............. ឆ្នាំ ជាតិ..................... មុខរបរ........................

ទីលំនៅភូមិ............................ ឃុំ..................... ស្រុក..................... ខេត្ត......................។

## សូមគោរពជូន

លោកប្រធានតុលាការគ្រួង........................

**កម្មវត្ថុ** : សុំប្តឹងលែងលះប្តីឈ្មោះ.......................... ភេទ.......... អាយុ.......... ឆ្នាំ សញ្ជាតិ...............
មុខរបរ........................ ។

នាងខ្ញុំសូមជំរាបជូនលោកប្រធានតុលាការដូចតទៅ ៖

នាងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ចំនួន............ឆ្នាំកន្លងមកហើយ ដូចមានសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី............ ខែ............... ឆ្នាំ.............. ធ្វើនៅសង្កាត់ភ្ជាប់មកជាមួយស្រាប់ ។ សព្វថ្ងៃនេះយើងខ្ញុំមាន កូនចំនួន........នាក់ និងមានទ្រព្យសម្បត្តិមួយចំនួន ។

ដោយប្តីរបស់នាងខ្ញុំចេះតែវាយដំលើរូបកាយរបស់នាងខ្ញុំ និងជេរប្រមាថមើលងាយលើញាតិ មិត្តបងប្អូនរបស់នាងខ្ញុំ ធ្វើអោយនាងខ្ញុំមិនអាចទ្រាំរស់នៅជាមួយគាត់តទៅទៀតបាន ទើបនាងខ្ញុំ សំរេចចិត្តសុំលែងលះគ្នា ចាប់តាំងពីពេលនេះតទៅ ។

ហេតុនេះ សូមលោកប្រធានតុលាការមេត្តាសំរេចចំពោះរឿងនេះអោយបានដាច់ស្រឡះ តាម សំណូមពរ ៖

- សុំផ្តាច់សមគ្គសង្វាស

www.budinst.gov.kh www.elibraryofcambodia.org

- សុំកូនចំនួន......នាក់ ឈ្មោះ..................និងឈ្មោះ........................
- សុំអោយឈ្មោះ..................ផ្តល់អាហារកិច្ចដល់កូនចំនួន.......នាក់
- សុំចែកទ្រព្យសម្បត្តិ................
- ផ្សេងៗ...................

សូមលោកប្រធានមេត្តាទទួលនូវការគោរពយ៉ាងជ្រាលជ្រៅអំពីនាងខ្ញុំ ។

ភ្នំពេញ, ថ្ងៃទី........ ខែ........ ឆ្នាំ...............

ហត្ថលេខា ឬស្នាមមេដៃស្តាំអ្នកប្តឹង

ឈ្មោះ..............................

**គំរូទី៩**

# ពាក្យបណ្តឹងសុំអោយកសាងទីលានបាញ់ស៊ីម

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្តឹង

ខ្ញុំបាទឈ្មោះ.........................អាយុ...............ឆ្នាំ ជាតិ....................មុខរបរ......................

ទីលំនៅភូមិ.....................ឃុំ....................ស្រុក....................ខេត្ត.....................តំណាងប្រជារាស្ត្រចំនួន............គ្រួសារនៅភូមិ............(១) និងភូមិ..........(២) ដូចមានឈ្មោះ និងស្នាមមេដៃជូនភ្ជាប់មកជាមួយស្រាប់ ។

## សូមគោរពជូន

លោកអភិបាលស្រុក...................

www.budinst.gov.kh www.elibraryofcambodia.org

កម្មវត្ថុ : លោកមេឃុំ........................ ។

ត្បិតយើងខ្ញុំទាំងអស់គ្នាជាប្រជារាស្ត្ររស់នៅក្នុងភូមិទាំងពីរខាងលើនេះ បានជួបផលវិបាក ក្នុងការរស់នៅយ៉ាងខ្លាំង នៅពេលមានការបាញ់ស៊ីបម្តងៗ ជាពិសេសរដូវបង្កបង្កើនផល និងប្រមូលផលស្រូវ ព្រោះការបាញ់ស៊ីបធ្វើអោយគ្រាប់ហើរប្រសេចប្រសាចទៅធ្លាក់ពេញវាលស្រែ ពេញភូមិ និងវត្តអារាម ដែលស្ថិតនៅជិតទីលាននោះ ហើយមានត្រូវរបួសសត្វពាហនៈ និងមនុស្សផង ។ ទីលានបាញ់ស៊ីបនេះ កាលដើមឡើយមានទំហំ និងកំពស់អាចទប់បាល់គ្រាប់មិនអោយខ្ទាតចេញក្រៅបាន តែបច្ចុប្បន្នមានការសឹករិចរឹលដោយសារធម្មជាតិមិនអាចទប់បាល់គ្រាប់ដូចពីមុនបានទេ តែគេនៅតែប្រើប្រាស់វាដដែល ។

ហេតុនេះ ដើម្បីទប់ស្កាត់នូវគ្រោះថ្នាក់ជាយថាហេតុ សូមលោកអភិបាលស្រុក មេត្តាធ្វើការដោះស្រាយកុំអោយគេប្រើទីលានបាញ់ស៊ីបនេះតទៅទៀត បើសិនជាមិនទាន់ជួសជុលអោយបានល្អដូចពីមុន ។

សូមលោកអភិបាលមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ភ្នំពេញ, ថ្ងៃទី.......... ខែ.............. ឆ្នាំ...............

ហត្ថលេខា ឬស្នាមមេដៃ

ឈ្មោះ..............................

**គំរូទី១០**

# ពាក្យបណ្តឹងមិនសុខចិត្តនឹងការចាក់សំរាមគ្មានអនាម័យ

៚៚៚៚

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្តឹង

អង្គការ...................... ទីស្នាក់ការផ្ទះលេខ........................ផ្លូវ.........................សង្កាត់......................

ខណ្ឌ........................ក្រុង........................ ។

**សូមគោរពជូន**
**លោកប្រធានក្រុមអនាម័យក្រុង**...........................

**កម្មវត្ថុ** : សុំប្តឹងទាមទារអោយលោក.........................ទីលំនៅផ្ទះលេខ..................ផ្លូវលេខ..........
សង្កាត់...................ខណ្ឌ...............................មុខងារជា.......................អោយកើបសំរាម និង
កុំអោយចាក់សំរាមនៅក្បែរផ្លូវចូលទីស្នាក់ការរបស់យើងខ្ញុំតទៅទៀត ។

យើងខ្ញុំសូមជំរាបលោកប្រធានក្រុមអនាម័យជ្រាបថា ៖

លោក..............................បានយកសំរាម និងកាកសំណល់ផ្សេងៗពីផ្ទះគាត់មកចាក់ចោលនៅខាងមុខទីស្នាក់ការរបស់យើងខ្ញុំក្បែរផ្លូវចូល ។ ការចាក់សំរាមខ្វះសណ្តាប់ធ្នាប់បែបនេះ មិនគប្បីភ្នែកភ្ញៀវដែលចេញចូលទំនាក់ទំនងការងារជាមួយអង្គការយើងខ្ញុំទេ ហើយវាថែមទាំងជះក្លិនស្អុយដល់បុគ្គលិករបស់អង្គការ ដែលកំពុងធ្វើការងារផង បញ្ហានេះយើងខ្ញុំតែងតែចាត់តំណាងរបស់អង្គការអោយទៅប្រាប់លោកម្ចាស់ផ្ទះជាញឹកញាប់ តែគេមិនយកចិត្តទុកដាក់នឹងសំដីរបស់តំណាងអង្គការយើងខ្ញុំទេ ។ ហេតុនេះ សូមលោកប្រធានក្រុមអនាម័យក្រុង ដែលតែងតែមើលការខុសត្រូវក្នុងក្រុង មេត្តាចាត់វិធានការអោយភ្នាក់ងាររបស់លោកទៅពិនិត្យមើលសំរាមនោះ និងសូមមេត្តាបង្គាប់អោយដឹកជញ្ជូនចេញ និងបញ្ឈប់ការស្តុកសំរាមនៅទីនេះតទៅទៀតដោយក្តីអនុគ្រោះ ។

សូមលោកប្រធានមេត្តាទទួលនូវសេចក្តីគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ភ្នំពេញ, ថ្ងៃទី............ខែ...............ឆ្នាំ...............

**ប្រធានអង្គការ**...........................

www.budinst.gov.kh www.elibraryofcambodia.org

## ផ្នែកទី៣

## បណ្តឹងទាស់

បណ្តឹងទាស់ ជាបណ្តឹងរបស់គូក្តីដែលប្តឹងមិនសុខចិត្តនឹងសាលក្រម ឬសាលដីការបស់តុលាការ ដែលសំរេចសេចក្តីកំបាំងមុខភាគីក្តីណាមួយ ហើយភាគីដែលអវត្តមាននោះ បានចូលរួមមកប្តឹងជំទាស់នឹងសាលក្រម ឬសាលដីកាកំបាំងមុខនោះ តាមកំណត់ច្បាប់ ។ បណ្តឹងទាស់អាចធ្វើបានក្នុងរយៈពេល១៥ថ្ងៃគត់ គិតចាប់ពីថ្ងៃបានទទួលដំណឹងពីសាលក្រមកំបាំងមុខ បើហួសរយៈពេល១៥ថ្ងៃ តុលាការមិនអាចទទួលបណ្តឹងនោះបានទេ ប៉ុន្តែសាមីខ្លួនអាចប្តឹងឧទ្ធរណ៍ក្នុងរយៈពេលពីរខែទៀតបាន ។

តាមគោលការណ៍បណ្តឹងទាស់ ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការ ដែលជំនុំជំរះរឿងក្តីនោះ ប៉ុន្តែគេអាចធ្វើបណ្តឹងទាស់បានដែរ តាមសំបុត្រអនុសិដ្ឋ ឬសំបុត្រធម្មតា ។

បណ្តឹងទាស់ផ្អាកការអនុវត្តន៍សាលក្រមកំបាំងមុខ ដែលចេញរួចហើយនោះ ហើយចៅក្រមមានសិទ្ធិពេញបរិបូណ៌ក្នុងការជំនុំជំរះឡើងវិញ ។

បើលើកទីពីរនេះ អ្នកប្តឹងទាស់នៅតែមិនចូលខ្លួនមកសវនាការតាមការកំណត់របស់តុលាការទេ តុលាការចេញសាលក្រមកំបាំងមុខលើកទីពីរទុកដូចជាចំពោះមុខ ពេលនោះសាមីខ្លួន ឬគូភាគីមិនអាចប្តឹងទាស់បានទៀតទេ តែអាចប្តឹងឧទ្ធរណ៍បាន ។

## គំរូពាក្យបណ្តឹងទាស់ជាសំបុត្រអនុសិដ្ឋ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្តឹងទាស់**

ខ្ញុំបាទឈ្មោះ..................................... អាយុ........................ឆ្នាំ មុខរបរ.............................. ទីលំនៅផ្ទះលេខ................................ ផ្លូវ.............................. សង្កាត់.................................. ខណ្ឌ.................................. ក្រុង...................................... ។

**សូមគោរពជូន**

**ចៅក្រមជំនុំជំរះ**..............................

www.budinst.gov.kh www.elibraryofcambodia.org

<u>កម្មវត្ថុ</u> ៖ សុំប្តឹងទាស់នឹងសាលក្រមកំបាំងមុខរបស់តុលាការក្រុង.................... លេខ..........................
ចុះថ្ងៃ............ខែ......................ឆ្នាំ......................។

តាមកម្មវត្ថុខាងលើនេះ សូមលោកចៅក្រម មេត្តាទទួលពាក្យបណ្តឹងទាស់របស់ខ្ញុំបាទ ដើម្បីជំនុំជំរះតាមច្បាប់ឡើងវិញដោយអនុគ្រោះ ។

សូមលោកចៅក្រមមេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

.................... ថ្ងៃទី.......... ខែ................ឆ្នាំ....................

ហត្ថលេខា ឬស្នាមមេដៃ

ឈ្មោះ..............................

## គំរូពាក្យបណ្តឹងទាស់ជាសំបុត្រអនុសិដ្ឋមួយបែបទៀត

### ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

### ពាក្យបណ្តឹងទាស់

ខ្ញុំបាទឈ្មោះ..............................អាយុ..................ឆ្នាំមុខរបរ.........................ទីលំនៅភូមិ..................
ឃុំ........................ស្រុក..........................ខេត្ត......................។

### សូមគោរពជូន
លោកចៅក្រមជំនុំជំរះនៃតុលាការ..............................

ខ្ញុំមានកិត្តិយស សូមជំរាបជូនលោកចៅក្រមដូចតទៅ ៖

តាមសាលក្រមលេខ......................ចុះថ្ងៃទី......................ខែ......................ឆ្នាំ.................. របស់តុលាការ
..............................................................................................................................
បានសំរេចអោយខ្ញុំបាទ..............................................................................................
..............................................................................................................................
សេចក្តីសំរេចនេះ ខ្ញុំបាទនៅពុំទាន់អស់ចិត្តសោះ ព្រោះ.................................................. ។

www.budinst.gov.kh www.elibraryofcambodia.org

............ ហេតុនេះ សូមលោកចៅក្រម មេត្តាយកសំណុំរឿងរបស់ខ្ញុំបាទមកពិនិត្យ និងកាត់ក្តីសាជាថ្មីម្តងទៀតដោយអនុគ្រោះ ។

សូមលោកចៅក្រមទទួលអំពីខ្ញុំបាទនូវសេចក្តីគោរព និងអំណរគុណយ៉ាងជ្រាលជ្រៅ ។

................ ថ្ងៃទី.......... ខែ................ ឆ្នាំ..................

**ហត្ថលេខា ឬស្នាមមេដៃ**

ឈ្មោះ................................

## ផ្នែកទី៤

## បណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ ជាបណ្តឹងដែលប្តឹងមិនសុខចិត្តនឹងសាលក្រម ឬសេចក្តីសំរេចនានា ឬដីការបស់តុលាការ ឬអយ្យការអមតុលាការថ្នាក់ក្រោម ( តុលាការខេត្ត-ក្រុង ឬតុលាការយោធា ) ។ បើគូក្តីមិនសុខចិត្តនឹងសាលក្រម ឬសេចក្តីសំរេចនោះដោយយល់ឃើញថា ការសំរេចរបស់តុលាការ ឬអយ្យការអមតុលាការថ្នាក់ក្រោមមិនត្រឹមត្រូវ ឬមិនយុត្តិធម៌ ។ បើចង់ប្តឹងឧទ្ធរណ៍ត្រូវចូលទៅប្តឹងអោយទាន់ក្នុងរយៈពេលពីរខែយ៉ាងយូរ គិតចាប់ពីថ្ងៃដែលតុលាការថ្នាក់ក្រោមបានចេញសាលក្រមតុលាការ ។ បើក្នុងរយៈពេលពីរខែនេះ មិនបានប្តឹងឧទ្ធរណ៍ទេ សាលក្រម ឬសេចក្តីសំរេចនឹងចូលជាស្ថាពរមិនអាចប្តឹងឧទ្ធរណ៍បានទេ ហើយក៏គ្មានវិធីណាអាចតវ៉ាបានដែរ លើកលែងតែមានភស្តុតាងត្រូវប្តឹងសើរើ ហើយករណីនេះ សំរាប់តែរឿងព្រហ្មទណ្ឌទេ បើជារឿងរដ្ឋប្បវេណីពុំអាចសើរើបានទេ ។

អ្នកដែលមានសិទ្ធិប្តឹងឧទ្ធរណ៍មាន ៖

- ជនជាប់ចោទ ឬអ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី
- ដើមបណ្តឹងរដ្ឋប្បវេណី
- ព្រះរាជអាជ្ញា
- មេធាវីរបស់គូក្តី បើសិនជាមាន

តាមគោលការណ៍បណ្តឹងឧទ្ធរណ៍ធ្វើដោយភាគីណាក៏ដោយ ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការ ដែលចេញសាលក្រម ។ អ្នកប្តឹងឧទ្ធរណ៍មិនចាំបាច់អោយដំណឹងនៃការប្តឹងរបស់ខ្លួននេះនៅភាគីផ្សេងទៀតទេ ។

www.budinst.gov.kh www.elibraryofcambodia.org

បណ្តឹងឧទ្ធរណ៍អាចធ្វើដោយសំបុត្រអនុសិដ្ឋ ឬសំបុត្រធម្មតាបានដែរ ប៉ុន្តែសំបុត្រនេះ ត្រូវផ្ញើទៅការិយាល័យក្រឡាបញ្ជីនៃតុលាការ ដែលចេញសាលក្រមនោះយ៉ាងរួសរាន់បំផុត ។ លិខិតនេះត្រូវមានបញ្ជាក់ច្បាស់អំពីចនុះអ្នកប្តឹងឧទ្ធរណ៍ដូចជា៖

១- តើប្តឹងមិនសុខចិត្តនឹងសាលក្រមអ្វី ? ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ឬតែចំណុចណាមួយ ?

២- តើប្តឹងមិនសុខចិត្តនឹងដីកាសំរេចអ្វី ? ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ឬតែចំណុចណាមួយ ?

ទម្រង់បណ្តឹងឧទ្ធរណ៍សំរាប់សាលក្រមសំណុំរឿង និងបណ្តឹងដែលអ្នកប្តឹងឧទ្ធរណ៍យល់ឃើញថា ត្រូវដាក់បន្ថែមលើបណ្តឹងឧទ្ធរណ៍របស់ខ្លួន ត្រូវបញ្ជូនទាំងអស់មកការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ក្នុងរយៈពេលយ៉ាងខ្លីបំផុត រួមទាំងជនជាប់ចោទដែលជាប់ពន្ធនាគារផង ចំពោះរឿងក្តីព្រហ្មទណ្ឌ ។

បណ្តឹងឧទ្ធរណ៍ផ្អាកការអនុវត្តន៍សាលក្រម ឬសេចក្តីសំរេចរបស់តុលាការ ឬអយ្យការអមតុលាការថ្នាក់ក្រោម រហូតដល់មានសេចក្តីសំរេចថ្មីរបស់សាលាឧទ្ធរណ៍ ហើយជាសេចក្តីសំរេចស្ថាពរ ។

* ចំពោះសាលក្រមកំបាំងមុខវិញ បើភាគីកំបាំងមុខនោះពុំបានប្តឹងទាស់ទេ គេមានសិទ្ធិប្តឹងឧទ្ធរណ៍រយៈពេល២ខែ១៥ថ្ងៃទៀត គិតពីថ្ងៃទទួលដំណឹងពីសាលក្រមកំបាំងមុខ ។

## គំរូពាក្យបណ្តឹងឧទ្ធរណ៍ផ្ញើទៅការិយាល័យក្រឡាបញ្ជី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការខេត្ត-ក្រុង

..............................

លេខ :.............................

ចុះថ្ងៃទី.........ខែ..........ឆ្នាំ...........

សំណុំរឿង.........................

លេខ :........ ចុះថ្ងៃទី........ខែ......ឆ្នាំ...........

**សេចក្តីសុំប្តឹងតវ៉ា**

ឆ្នាំ..........................ខែ..........ថ្ងៃទី............ វេលាម៉ោង.................. ។

www.budinst.gov.kh www.elibraryofcambodia.org

យើង........................................ក្រឡាបញ្ជី.......................................................................... ។

បានឃើញឈ្មោះ...................................................................................................................

ចូលមកចំពោះមុខយើងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការ...................................................

ហើយសុំប្តឹង..........................................................និង...........................................................

លេខ.......................ចុះថ្ងៃទី...............ខែ...........................ឆ្នាំ...............................................

ត្រង់ចំណុច..........................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

ឈ្មោះនេះទទួលថា នឹងធ្វើពាក្យបណ្តឹងបន្ថែមអោយទាន់ពេលវេលា ។

ក្រែងពុំប្រាកដ យើងបានសូត្រសេចក្តីនេះអោយឈ្មោះ.......................................................

ស្តាប់ ហើយអោយចុះហត្ថលេខា ឬផ្តិតមេដៃជាមួយយើង ។

អ្នកប្តឹង | ក្រឡាបញ្ជី
ស្នាមមេដៃ ឬហត្ថលេខា | ហត្ថលេខា

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

.....................ថ្ងៃទី...........ខែ...........ឆ្នាំ...............

ក្រឡាបញ្ជី

www.budinst.gov.kh www.elibraryofcambodia.org

# គំរូពាក្យបណ្ដឹងឧទ្ធរណ៍ជាសំបុត្រអនុសិដ្ឋ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្ដឹងឧទ្ធរណ៍

ខ្ញុំបាទឈ្មោះ..................អាយុ..................ឆ្នាំមុខរបរ..................ទីលំនៅផ្ទះលេខ.........
ផ្លូវ..................សង្កាត់..................ខណ្ឌ..................ក្រុង..................។

### សូមគោរពជូន
### លោកប្រធានតុលាការ..................

**កម្មវត្ថុ** : សុំប្ដឹងឧទ្ធរណ៍លើសាលក្រមរដ្ឋប្បវេណីរបស់តុលាការក្រុងព្រះសីហនុលេខ..................
ចុះថ្ងៃទី..........ខែ..........ឆ្នាំ..........។

ខ្ញុំបាទមានកិត្តិយស សូមជំរាបជូនលោកប្រធានតុលាការដើម្បីជ្រាបថា ៖

សាលក្រមរបស់តុលាការក្រុងព្រះសីហនុខាងលើនេះ សំរេចសេចក្ដីមិនយុត្តិធម៌ទេ ដោយហេតុថា ដីទំហំ១០០ហិកតា ដែលស្ថិតនៅតំបន់ស្ពានទឹកសាប ខ្ញុំបាទបានកាប់ឆ្ការ កាន់កាប់ប្រើប្រាស់ បង្កបង្កើនផលដំណាំតាំងពីឆ្នាំ១៩៨៣មក រហូតដល់បច្ចុប្បន្ននេះ មិនដែលបោះបង់ចោលម្ដងណាទេ ស្រាប់តែក្នុងឆ្នាំ១៩៩៣ ឈ្មោះ " ៩ " បានសុំការអនុញ្ញាតពីរដ្ឋអំណាចខណ្ឌព្រៃនប់យកដីរបស់ខ្ញុំធ្វើជាសកម្មសិទ្ធិរបស់គេ ។ ដីនេះ ទោះបីខ្ញុំបាទមិនទាន់បានសុំការអនុញ្ញាតពីរដ្ឋអំណាចក៏ដោយ ក៏ខ្ញុំបាទជាអ្នករុករាន គ្រប់គ្រងប្រើប្រាស់រហូតមកដែរ ខ្ញុំបាទមិនអាចប្រគល់ទៅអោយឈ្មោះ " ៩ " បានទេ ។ មូលហេតុដែលខ្ញុំបាទមិនទាន់បានសុំការអនុញ្ញាតកាន់កាប់ ព្រោះទីនោះពីមុនមក ជាដីបំរុងរបស់រដ្ឋ ។ ទើបតែនៅពេលមានទំនាស់ជាមួយឈ្មោះ " ៩ " ទើបខ្ញុំបាទដឹងថា រដ្ឋអនុញ្ញាតឱ្យប្រជារាស្ត្រមានសិទ្ធិកាន់កាប់ដីតំបន់ទឹកសាបជាកម្មសិទ្ធិ ។ ឈ្មោះ " ៩ " ជាមន្ត្រីរាជការក្នុងខណ្ឌព្រៃនប់ គេបានដឹងពត៌មានស្ដីពីការអនុញ្ញាតកម្មសិទ្ធិជូនប្រជារាស្ត្រធម្មតា ទើបគេសុំយកដីដែលខ្ញុំបាទកំពុងកាន់កាប់ធ្វើជាកម្មសិទ្ធិរបស់គេតែម្ដង ។

www.budinst.gov.kh www.elibraryofcambodia.org

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាទទួលចុះបណ្តឹងឧទ្ធរណ៍របស់ខ្ញុំបាទតាមច្បាប់ដោយអនុគ្រោះ ។

ក្រុងព្រះសីហនុ, ថ្ងៃទី.........ខែ.............ឆ្នាំ.............

ហត្ថលេខា ឬស្នាមមេដៃស្តាំ

ឈ្មោះ.................................

## គំរូពាក្យបណ្តឹងឧទ្ធរណ៍ជាសំណុំរឿងអនុសិដ្ឋមួយបែបទៀត

### ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

### ពាក្យបណ្តឹង

ខ្ញុំបាទឈ្មោះ.............................អាយុ..............ឆ្នាំ សញ្ជាតិ................ទីលំនៅផ្ទះលេខ..........................

សង្កាត់..............................ខណ្ឌ.......................ក្រុង.......................... ។

### សូមគោរពជូន
### លោកចៅក្រមជំនុំជំរះតុលាការ...........................

ខ្ញុំបាទពុំសុខចិត្តនឹងការកាត់ក្តីរបស់ខ្ញុំបាទនៅតុលាការ..................តាមសាលក្រម លេខ..........
ចុះថ្ងៃទី.............ខែ..................ឆ្នាំ..................ចំណុច............................ ។

ហេតុនេះខ្ញុំបាទ សូមលោកចៅក្រមមេត្តាបញ្ជូនសំណុំរឿងរបស់ខ្ញុំបាទទៅកាន់សាលាឧទ្ធរណ៍ដើម្បីពិនិត្យកាត់ក្តីសាជាថ្មីដោយយុត្តិធម៌អោយខ្ញុំបាទដោយអនុគ្រោះ ។

សូមលោកចៅក្រម មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ធ្វើនៅ...................ថ្ងៃទី.............ខែ..............ឆ្នាំ...............

ហត្ថលេខា ឬស្នាមមេដៃ

www.budinst.gov.kh www.elibraryofcambodia.org

ផ្នែកទី៥

## បណ្ដឹងសាទុក្ខ

បណ្ដឹងសាទុក្ខ ជាបណ្ដឹងដែលគូក្ដី ឬអ្នកដែលមានប្រយោជន៍ក្នុងរឿងក្ដី ឬបុគ្គលដែលច្បាប់ទទួលស្គាល់ជាតំណាងត្រឹមត្រូវតាមច្បាប់ ប្ដឹងមិនសុខចិត្តនឹងការសំរេចសេចក្ដី ឬសាលដីការបស់សាលាឧទ្ធរណ៍ ។

នៅគ្រប់ករណីទាំងអស់ បណ្ដឹងសាទុក្ខត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការសាលាឧទ្ធរណ៍ ។ បណ្ដឹងនេះត្រូវទុកនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ដើម្បីបញ្ជូនទាំងបណ្ដឹងទាំងសំណុំរឿងទៅកាន់តុលាការកំពូលយ៉ាងឆាប់បំផុត ។

គូក្ដីមានសិទ្ធិប្ដឹងសាទុក្ខក្នុងរយៈពេលពីរខែគត់ គិតចាប់ពីថ្ងៃប្រកាសសាលដីការបស់សាលាឧទ្ធរណ៍ ឬពីរខែគត់ ចាប់ពីថ្ងៃផុតកំណត់ប្ដឹងទាស់ចំពោះសាលដីកាកំបាំងមុខរបស់សាលាឧទ្ធរណ៍ ។

បណ្ដឹងសាទុក្ខអាចមានពីរដង កាលបើមានការកើតទុក្ខមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ទាំងពីរលើកក្នុងរឿងក្ដីតែមួយដដែលៗ ។

* **សំគាល់**

ករណីរឿងក្ដីទៅដល់សាលាឧទ្ធរណ៍ហើយ គូភាគីគួរតែរកមេធាវី ដើម្បីប្រាស្រ័យទាក់ទងអំពីច្បាប់ បើគ្មានប្រាក់ជួលមេធាវី ត្រូវទៅរកអង្គភាពរដ្ឋណាមួយ ឬអង្គការណាមួយ ដើម្បីឱ្យគេជួយបង្ហាញអាសយដ្ឋានរបស់មេធាវីការពារជនក្រីក្រ ដោយឥតយកប្រាក់ ។

www.budinst.gov.kh www.elibraryofcambodia.org

# គំរូពាក្យបណ្តឹងសាទុក្ខធ្វើនៅការិយាល័យក្រឡាបញ្ជី

ព្រះរាជាណាចក្រកម្ពុជា

សាលាឧទ្ធរណ៍ ជាតិ សាសនា ព្រះមហាក្សត្រ

...................

លេខ..........

ចុះថ្ងៃទី.......ខែ........ឆ្នាំ..........

## សេចក្តីសុំប្តឹងតវ៉ា

សំសុំរឿង...............

លេខ :............ ចុះថ្ងៃទី............ខែ..............ឆ្នាំ.............

ឆ្នាំ..................................ខែ..................ថ្ងៃទី.................. វេលា ម៉ោង.......................។

យើង...............................ក្រឡាបញ្ជី.......................................................................។

បានឃើញឈ្មោះ..................................................................................................

ចូលមកចំពោះមុខយើងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការ.........................................

ហើយសុំប្តឹង........................................., ..........និង.......................................

លេខ.....................ចុះថ្ងៃទី.................ខែ..........................ឆ្នាំ..................................

ត្រង់ចំណុច.........................................................................................................

.........................................................................................................................

.........................................................................................................................

ឈ្មោះនេះទទួលថា នឹងធ្វើពាក្យបណ្តឹងបន្ថែមអោយទាន់ពេលវេលា ។

ត្រែងពុំប្រាកដ យើងបានសូត្រសេចក្តីនេះអោយឈ្មោះ.............................................

ស្តាប់ ហើយអោយចុះហត្ថលេខា ឬផ្តិតមេដៃជាមួយយើង ។

អ្នកប្តឹង ក្រឡាបញ្ជី

ស្នាមមេដៃ ឬហត្ថលេខា ហត្ថលេខា

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

.............ថ្ងៃទី..........ខែ..........ឆ្នាំ..............

ក្រឡាបញ្ជី

www.budinst.gov.kh www.elibraryofcambodia.org

# ផ្នែកទី៦

## បណ្តឹងសើរើ

បណ្តឹងសើរើ គឺជាការប្តឹងតវ៉ាមិនសុខចិត្តនឹងសាលក្រមរបស់តុលាការខេត្ត-ក្រុង តុលាការយោធា ឬសាលដីការបស់សាលាឧទ្ធរណ៍ ឬសាលដីការបស់តុលាការកំពូល ដែលបានចូលជាស្ថាពរ និងមានអំណាចដាច់ខាតរួចទៅហើយ ។

សិទ្ធិប្តឹងសើរើអាចធ្វើបានក្នុងរឿងក្តីព្រហ្មទណ្ឌ ទោះជារឿងនោះមានទំហំប៉ុនណាក៏ដោយ ដូចជា ៖

១ - កាលណាក្រោយពីការផ្តន្ទាទោសពីបទធ្វើមនុស្សឃាត ស្រាប់តែមានភស្តុតាងបញ្ជាក់អោយឃើញច្បាស់លាស់ថា ជនរងគ្រោះនៅមានជីវិតនៅឡើយ ។

២ - កាលណាក្រោយពីការផ្តន្ទាពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ស្រាប់តែមានសាលក្រម ឬសាលដីកាថ្មីមួយទៀត សំរេចផ្តន្ទាទោសជនជាប់ចោទម្នាក់ទៀត ចំពោះអង្គសេចក្តីដដែលដោយគ្មានអ្វីបញ្ជាក់ថា រវាងអ្នកទាំងពីរមានការសមគំនិត ឬសហការអ្វីឡើយ ហើយការផ្តន្ទាទោសទាំងពីរនេះ ពុំមានការទាក់ទងគ្នាឡើយ ។

ភាពផ្ទុយគ្នានេះ ជាភស្តុតាងនៃភាពសុចរិត ស្លូតត្រង់របស់ទណ្ឌិតណាមួយក្នុងបណ្តាទណ្ឌិតទាំងពីរ ។

៣ - កាលណាសាក្សីណាមួយ ត្រូវបានតុលាការយកចម្លើយរួចហើយ ហើយក្រោយមកសាក្សីនោះត្រូវបានតុលាការផ្តន្ទាទោសដាក់គុកក្នុងរឿងធ្វើសាក្សីទុច្ចរិត ដាក់បន្ទុកលើជនជាប់ចោទ ហើយបើគ្មានសាក្សីទុច្ចរិតនោះទេ ភាពសុចរិតរបស់ទណ្ឌិតត្រូវតែមាន ។

៤ កាលណាក្រោយពីការផ្តន្ទាទោសព្រហ្មទណ្ឌអង្គហេតុថ្មីបានកើតមាន ឬកាលណាវត្ថុតាង ដែលគ្មាននៅពេលសួរដេញដោល ស្រាប់តែមាននៅពេលនោះ ហើយអង្គហេតុ ឬវត្ថុតាងទាំងនោះ ជាហេតុអោយបញ្ជាក់បាននូវភាពសុចរិត ស្លូតត្រង់របស់ទណ្ឌិត ។

ក្នុងគ្រប់ករណីទាំងអស់ អ្នកដែលមានសិទ្ធិសុំអោយជំនុំជំរះសើរើ គឺ ៖

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- ទណ្ឌិត ឬតំណាងពេញច្បាប់របស់ទណ្ឌិតក្នុងករណីទណ្ឌិតអសមត្ថភាព

www.budhist.gov.kh www.elibraryofcambodia.org

សហព័ទ្ធឪពុក ម្ដាយ កូនរបស់ទណ្ឌិតនិយាយរួមជនដែលមានប្រយោជន៍ខាងផ្នែកសំភារៈ ឬខាងផ្លូវចិត្ត កាលណាទណ្ឌិតនោះស្លាប់ ឬបាត់ខ្លួន ។ បណ្ដឹងសើរើត្រូវបានតុលាការកំពូលទទួលជំនុំជំរះចេញសាលដីកា ក្នុងរយៈពេល៨ថ្ងៃយ៉ាងយូរចាប់ពីថ្ងៃបានទទួលនៃបណ្ដឹងសើរើ ។ បណ្ដឹងសើរើមានអានុភាពនាំអោយលើករឿងទាំងអស់អោយតុលាការកំពូលជំនុំជំរះ ។

សាលដីការបស់តុលាការកំពូល ដែលសំរេចថាទណ្ឌិតជាជនសុគតត្រង់រួចខ្លួននោះ ត្រូវតែយកទៅបិទនៅសាលាជំនុំជំរះក្ដីដែលបានជំនុំជំរះរឿង និងនៅទីស្នាក់ការឃុំ ឬសង្កាត់នៃលំនៅដ្ឋានរបស់ទណ្ឌិត ។

## គំរូពាក្យបណ្ដឹងសើរើ

### ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្ដឹងសើរើ

ខ្ញុំបាទឈ្មោះ.................................អាយុ..................ឆ្នាំ ជាតិ.......................មុខរបរ.........................
ទីលំនៅភូមិ.............................ឃុំ.......................ស្រុក.........................ខេត្ត........................... ។

### សូមគោរពជូន
**ឯកឧត្ដម ប្រធានតុលាការកំពូល**..............................

**កម្មវត្ថុ** : សុំប្ដឹងសើរើសំណុំរឿងឈ្មោះ..........................................

តាមកម្មវត្ថុខាងលើនេះ ខ្ញុំបាទសូមជំរាបជូនឯកឧត្ដម ដើម្បីជ្រាបថា ៖

កូនរបស់ខ្ញុំបាទឈ្មោះ...............................ត្រូវបានតុលាការខេត្តក្រចេះផ្ដន្ទាទោសពីបទរំលោភតាមសាលក្រមលេខ....................ចុះថ្ងៃទី...................ខែ........................ឆ្នាំ.....................នៃសំណុំរឿងព្រហ្មទណ្ឌលេខ............................ចុះថ្ងៃទី...............ខែ...............ឆ្នាំ.................. ។

សាលក្រមដែលផ្ដន្ទាទោសកូនរបស់ខ្ញុំបាទ បានចូលជាស្ថាពរអស់រយៈពេល២ឆ្នាំកន្លងមកហើយ ។ ទើបតែនៅថ្ងៃទី..............ខែ...............ឆ្នាំ...................ខ្ញុំបាទបានចូលទៅស្រេស្រូបអាហារពេល

www.budinst.gov.kh www.elibraryofcambodia.org

ព្រឹកនៅក្នុងអាហារដ្ឋានមួយ ខ្ញុំបាទបានឮឈ្មោះ..............................និយាយជាមួយមិត្តភ័ក្ត្ររបស់គេម្នាក់ថា ពាក់ព័ន្ធនឹងការចោទប្រកាន់លើឈ្មោះ.............................. កាលពីឆ្នាំ..................តាមពិតខ្លួនអត់បានដឹងរឿងអ្វីទាំងអស់ តែខ្លួនអាចចូលទៅឆ្លើយចំពោះមុខតុលាការបាន ព្រោះខាងដើមបណ្ដឹងគេបង្គាប់អោយនិយាយ ពេលដែលខ្លួននិយាយ តុលាការក៏ជឿហើយយកធ្វើភស្តុតាងផ្តន្ទាទោសឈ្មោះ..............រហូតដល់៥ឆ្នាំ ។

ករណីនេះ ខ្ញុំបាទបានប្តឹងពីឈ្មោះ........................ពីបទផ្តល់សក្ខីកម្មក្លែងក្លាយ តុលាការក៏បានផ្តន្ទាទោសជននោះរួចហើយ ចំណែកកូនរបស់ខ្ញុំនៅតែជាប់គុកដដែល ។

ហេតុនេះ សូមឯកឧត្តម មេត្តាសេរីវត្តិដែលទាក់ទងនឹងកូនរបស់ខ្ញុំបាទ ឈ្មោះ........................មកពិនិត្យ ដើម្បីជំនុំជំរះឡើងវិញដោយគតិយុត្តិធម៌ ។

ធ្វើនៅ..................ថ្ងៃទី.........ខែ...........ឆ្នាំ................

**ហត្ថលេខា ឬស្នាមមេដៃស្តាំ**

**ឈ្មោះ**...............................

www.budinst.gov.kh www.elibraryofcambodia.org

# គំរូពាក្យបណ្ដឹងសើរើមួយបែបទៀត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្ដឹង

ខ្ញុំបាទឈ្មោះ.......................................អាយុ.......................ឆ្នាំ សញ្ជាតិ.......................មុខរបរ...........................

ទីលំនៅភូមិ.................................ឃុំ.................................ស្រុក.......................ខេត្ត.........................ត្រូវជាបងស្រី

របស់ទណ្ឌិតឈ្មោះ........................ ។

### សូមគោរពជូន

ឯកឧត្ដម ប្រធានតុលាការកំពូល...............................

ត្បិតកាលពីថ្ងៃទី.........ខែ.....................ឆ្នាំ.....................តុលាការខេត្តតាកែវ បានបើកសវនាការជំនុំជំរះសំណុំរឿងព្រហ្មទណ្ឌលេខ.................ចុះថ្ងៃទី............ខែ..............ឆ្នាំ...................ហើយបានផ្ដន្ទាទោសប្អូនប្រុសរបស់នាងខ្ញុំឈ្មោះ......................ក្នុងរយៈពេលប្រាំបីឆ្នាំពីបទសមគំនិតសម្លាប់ឈ្មោះ...................ជាមួយជនល្មើសដែលឈ្មោះ..............................មួយ និងឈ្មោះ............................មួយ ទោសនោះមានកំណត់៨ឆ្នាំ ។ ក្រោយពីទទួលទោសបាន៤ឆ្នាំ ស្រាប់តែគេស្វែងរកចាប់ខ្លួនជនល្មើសដែលបាន ហើយធ្វើការសាកសួរជនល្មើសឈ្មោះ.........................ជននោះបានឆ្លើយថា កាលពីសម្លាប់ឈ្មោះ........ ............................ក្រោយពេលសម្លាប់រួច ពួកគេបាននាំគ្នាគេចខ្លួនបាត់អស់ទៅរស់នៅឯខេត្តបាត់ដំបង ចំណែកឈ្មោះ............................ ជាប្អូនរបស់នាងខ្ញុំ ពួកគេមិនដែលស្គាល់ទេ ។

នាងខ្ញុំសូមបញ្ជាក់ថា កាលពីឈ្មោះ..........................នៅរស់ ប្អូនរបស់នាងខ្ញុំឈ្មោះ.....................ធ្លាប់មានទំនាស់បន្តិចបន្តួចមែន តែពេលឈ្មោះ........................ស្លាប់ ប្អូនរបស់នាងខ្ញុំមិនបានដឹងរឿងហេតុទេ ជាការចៃដន្យបំផុតដែលប្អូនរបស់នាងខ្ញុំបានដើរទៅប្រទះសាកសពរបស់ឈ្មោះ..................... ស្លាប់នៅខាងក្រោយភូមិចំងាយ១០០ម៉ែត្រ ហើយបានមករាយការណ៍ប្រាប់ប្រធានភូមិ ប្រធានភូមិបាននាំគ្នាទៅមើលសាកសព ហើយស្វែងរកជនល្មើស នៅពេលរកជនល្មើសមិនឃើញ ក្រុមគ្រួសាររបស់ជនរងគ្រោះ និងអ្នកភូមិក៏សន្និដ្ឋានថា ច្បាស់ជាប្អូនប្រុសរបស់នាងខ្ញុំជាអ្នកសម្លាប់តែម្ដង ព្រោះប្អូនរបស់នាងខ្ញុំ និងជនរងគ្រោះឈ្មោះ...............................ធ្លាប់ឈ្លោះគ្នា និងធ្លាប់មានគំនុំនឹងគ្នាផង ។

www.budinst.gov.kh www.elibraryofcambodia.org

អាស្រ័យហេតុនេះ សូមឯកឧត្តមប្រធាន មេត្តាសើរើសំណុំរឿងខាងលើ យកមកពិនិត្យសំរេចឡើងវិញដោយអនុគ្រោះ ។

ធ្វើនៅ.............. ថ្ងៃទី............ ខែ............. ឆ្នាំ..............

**ហត្ថលេខា ឬស្នាមមេដៃស្តាំ**

**ឈ្មោះ**...........................

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ សូមថ្លែងអំណរគុណចំពោះអស់លោក លោកស្រីទាំងអស់ ដែលបានយកចិត្តទុកដាក់ក្នុងការអានសៀវភៅនេះពីដើមរហូតដល់ចប់ ។

នេះជាស្នាដៃទីមួយដ៏ស្តួចស្តើង ដែលផុសចេញពីគំនិតដ៏ក្មេងខ្ចីរបស់អ្នករៀបរៀងសំរាប់ផ្តល់ជាជំនួយស្មារតីដល់ពលរដ្ឋ ដែលពុំសូវយល់អំពីរបៀបរបបធ្វើពាក្យបណ្តឹង និងមិនទាន់ស្គាល់ច្បាប់នូវផ្លូវដែលបណ្តឹងត្រូវដើរ ។

ឆ្លងកាត់បទពិសោធន៍ការងារខាងវិស័យច្បាប់មួយរយៈកាលកន្លងមកនេះ អ្នករៀបរៀងមើលឃើញថា ពលរដ្ឋខ្មែរភាគច្រើនតែងតែមានរឿងរ៉ាវប្តឹងគ្នាស្ទើរតែមិនចេះចប់ អ្នកខ្លះរឿងមួយសឹងមិនទាន់ចប់ផង រឿងមួយទៀតចូលមកដល់អស់ពីអ្នកនេះមានរឿង អ្នកនោះមានរឿង ព្រោះតែក្តីក្តាំ អ្នកខ្លះស្ទើរតែវង្វេងស្មារតីដោយទីមួយគិតទៅលើបញ្ហាដែលកើតឡើង ទីពីរមិនដឹងថា តើត្រូវដោះស្រាយយ៉ាងណា តើអ្នកណាខ្លះអាចជួយដោះស្រាយបញ្ហាអោយខ្លួនបាន នេះដោយសារតែការមិនសូវយល់ដូចកវីក្រមង៉ុយ លោកថែងថា " **ល្ងង់ដប់ចេះពីរបី ចេះដ្ឋញត្តិមិនចេះច្បាប់ មិនចេះលេខអក្សរមុខមាត់ល្អប្រាជ្ញាអប្ប ឈ្មោះខ្លួនខ្លែកត្លីស្រាប់ គេសូត្រប្រាប់ទើបបានដឹង** " ។ ដោយមើលឃើញបែបនេះហើយ ទើបអ្នករៀបរៀងផុសចេញនូវគំនិតរៀបចំឯកសារ ស្តីពី " **ផ្លូវនៃបណ្តឹង** " នេះឡើង ។

ទោះបីឯកសារនេះធ្វើឡើងមិនបានល្អ ឬមិនគ្រប់គ្រាន់ក្តី អ្នករៀបរៀងសង្ឃឹមថា អស់លោកអ្នកអានប្រាកដជាខន្តីអភ័យទោស និងជួយលើកមតិរិះគន់ស្ថាបនាមិនខានឡើយ ។

អ្នករៀបរៀង សូមឧទ្ទិសអោយឯកសារនេះក្លាយទៅជាមិត្តដ៏ល្អរបស់អស់លោកអ្នក និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការយកចិត្តទុកដាក់ ។

www.budinst.gov.kh www.elibraryofcambodia.org

# ឯកសារពិគ្រោះ

១ - ច្បាប់សិទ្ធិមនុស្សអន្តរជាតិ

២ - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

៣ - ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា

៤ - ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

៥ - ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌអន្តរកាល

៦ - ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

៧ - ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ

៨ - ច្បាប់ភូមិបាល

៩ - ច្បាប់កិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា

១០- ច្បាប់ក្រមង៉ុយ

១១ - សារាចរណែនាំនានារបស់ក្រសួងយុត្តិធម៌

១២ - មេរៀនស្តីពីនីតិវិធីរដ្ឋប្បវេណីរបស់លោកមេធាវី ហេង ឌី

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org